ការប្រើវិធីបង្រៀនកំណត់ត្រាអំណាន ដើម្បីជំរុញការអានយល់ន័យ របស់សិស្សថ្នាក់ទី៦ មុខវិជ្ជាភាសាខ្មែរ

Using Reading Log for Improving Comprehensive Reading for Students Grade 6

ផន សុជាតា[1] ង្ហួន សំអុល[2]

PHON Socheata, NGUON Sam OL

សង្ខិត្តន័យ

ការអានមានសារសំខាន់សម្រាប់អ្នកសិក្សា ជាពិសេសកុមារនៅកម្រិតបឋមសិក្សា។ អាស្រ័យហេតុដូច្នេះហើយ បានជាកម្មវិធីសិក្សារបស់ក្រសួងអប់រំ យុវជន និងកីឡាប្រមាណ៥0% ផ្តោតសំខាន់លើការអាន ប៉ុន្តែការវាយតម្លៃទាំងកម្រិតជាតិ និងអន្តរជាតិបង្ហាញថា ការអានរបស់កុមារនៅកម្រិតថ្នាក់ទី៦នៅតែពុំទាន់បានប្រសើរនៅឡើយ។ គោលបំណងនៃការសិក្សានេះគឺ ដើម្បីពិនិត្យមើលប្រសិទ្ធភាពនៃការប្រើកំណត់ត្រាអំណានលើការអានយល់ន័យរបស់សិស្សថ្នាក់ទី៦ ដោយធ្វើការស្រាវជ្រាវតាមបែបពិសោធវិធីសាស្ត្រ ព្រមទាំងស្វែងយល់ទស្សនៈយល់ឃើញអំពីការប្រើកំណត់ត្រាអំណាន ក្នុងការជំរុញការអានយល់ន័យរបស់សិស្ស ក្រោយពេលអនុវត្តវិធី កំណត់ត្រាអំណាន។ ការសិក្សាស្រាវជ្រាវនេះបានជ្រើសរើសយកការស្រាវជ្រាវតាមបរិមាណវិស័យ និងគុណវិស័យ ដោយធ្វើការប្រមូលទិន្នន័យពីសិស្សថ្នាក់ទី៦ចំនួន២ថ្នាក់គឺថ្នាក់ពិសោធ(N=39) និងថ្នាក់ត្រួតពពិនិត្យ(N=32) ដោយជ្រើសចេញពីសាលាបឋមសិក្សាមួយនៅទីក្រុងភ្នំពេញ។ បំណែកឯការសម្ភាសវិញ សិស្សចំនួន៦នាក់ បានជ្រើសចេញពីថ្នាក់ពិសោធន៍ដោយប្រើការជ្រើសរើសតាមបែបចៃដន្យធម្មតា(Simple random)។ ការពិសោធនេះប្រើរយៈពេល១0សប្តាហ៍ ដោយថ្នាក់ពិសោធប្រើវិធីកំណត់ត្រាអំណាន ខណៈពេលដែលក្រុមត្រួតពិនិត្យប្រើវិធីបែបប្រពៃណី។ ការប្រមូលទិន្នន័យធ្វើឡើងនូវមុនពេល និងក្រោយពេលពិសោធតាមរយៈតេស្តលទ្ធផលសិក្សា ឯការសម្ភាស ធ្វើឡើងនៅក្រោយពេលអនុវត្តវិធីកំណត់ត្រាអំណាន។ លទ្ធផលដែលបានមកពីការវិភាគតាមANCOVA បង្ហាញថា $F(1, 68) = 27.73, P < 0.05, Partial J^2 = 0.13$ មានន័យថាការប្រើវិធីកំណត់ត្រាអំណាននេះ មានប្រសិទ្ធភាពលើលទ្ធផលនៃការសិក្សារបស់សិស្ស។ បំពោះការប្រើវិធីនេះ សិស្សមានទស្សនៈយល់ឃើញវិជ្ជមានទៅលើការប្រើប្រាស់វិធីខាងលើ ក្នុងការជំរុញការអានយល់ន័យនេះផងដែរ។ ការស្រាវជ្រាវនេះបានបន្ថែមលើទ្រឹស្តីដែលបានរកឃើញមុនៗ ដែលបង្ហាញថាវិធីកំណត់ត្រាអំណានពិតជាបានចូលរួមចំណែកក្នុងការបង្កើនការអានយល់ន័យរបស់សិស្សប្រាកដមែន ហើយការស្រាវជ្រាវនេះក៏បង្ហាញពីភាពចាំបាច់នៃការប្រើវិធីនេះនៅកម្រិតបឋមផងដែរ ដោយហេតុថា នេះជាគន្លឹះដ៏សំខាន់ក្នុងការកសាងទម្លាប់អាននៅកម្ពុជា។

ពាក្យគន្លឹះ៖ កំណត់ត្រាអំណាន អំណាន ការអានយល់ន័យ

១. គរុនិស្សិត ១២+ ៤ ជំនាន់ទី២ (២0២២-២0២៣) ឯកទេសបង្រៀននៅបឋមសិក្សា២. គ្រូឧទ្ទេសដឹកនាំ

ABSTRACT

Reading is important for learners, especially students in primary school. As a result, about 50% of the Ministry of Education, Youth and Sport's curriculum focuses on reading, but both national and international assessments showed that students' reading in grade 6 is still not good. The purpose of this study was to examine the effectiveness of reading log on the reading comprehension of sixth graders by conducting an experimental research design and exploring perspectives on the use of reading log methods to promote reading comprehension after applying the reading log method. The study selected quantitative, and qualitative methods by collecting data from two grade 6 students: an experimental group (N = 39) and a control group (N = 32) selected from a primary school in Phnom Penh. As for the interviews, six students were randomly selected from the experimental group. For 10 weeks, the experimental group used the reading log method, while the control group used the traditional teaching method. Data were collected before and after the experiment through achievement tests, and interviews were conducted after applying the reading log method. The results from the ANCOVA analysis show that $F(1, 68) = 27.73, P < 0.05$, $Partial\ \mu^2 = 0.13$ means that the use of this reading log method has an effect on student learning outcomes. For the use of this method, students have a positive view of the use of the above method to promote reading comprehension. This research adds to the previously found literature, showing that reading comprehension methods have indeed contributed to increasing students' reading comprehension and that this research also demonstrates the need to use this method at the primary level because this is the key to building a reading habit in Cambodia.

Key word: *reading log; reading; comprehensive reading*

១. សេចក្តីផ្តើម

ប្រទេសកម្ពុជាជាប្រទេសកំពុងអភិវឌ្ឍដែលកំពុងស្រេកឃ្លានឆ្ងាយធនធានមនុស្សជាច្រើន។ ទន្ទឹមជាមួយគ្នានេះដែរ វិស័យអប់រំបានរួមចំណែកយ៉ាងធំដល់ការអភិវឌ្ឍធនធានមនុស្សក្នុងសង្គម។ ក្រសួងអប់រំយុវជន និងកីឡា(អយក.)បានខិតខំប្រឹងប្រែង បានដាក់បញ្ចូលនូវវិធីសាស្ត្របង្រៀនថ្មីៗ និងកំណែទម្រង់ផ្សេងៗ ក្នុងន័យកែប្រែគុណភាពអប់រំកាន់តែប្រសើរ(Hang, 2016)។ ក្នុងន័យនៃការអប់រំ

ក៏ដូចជាការអភិវឌ្ឍធនធានមនុស្សផងដែរ អយក.បានយកចិត្តទុកដាក់លើវិស័យអំណាន ដោយវាលេចចេញជារូបភាពផ្សេងៗដូចជា មហោស្រពអំណានថ្នាក់ជាតិ ការតាំងពិពណ៌សៀវភៅ ឬការលើកកម្ពស់អំណានដំបូងជាដើម (MoEYS, 2020; Royal Government of Cambodia, 2015)។

ក្នុងវិស័យអប់រំរបស់ប្រទេសកម្ពុជា អំណានត្រូវបានប្រទះឃើញតាំងពីថ្នាក់ដំបូងក្នុងបឋមសិក្សា ក្នុងរូបភាពជាពាក្យ ល្បះ ឬអត្ថបទខ្លីជាដើម (MoEYS, 2020)។ ក្នុងនោះដែរ ការអានយល់ន័យគឺជាកម្រិតនៃការអានដែលជួយដល់អ្នកអានអាចទទួលបានអត្ថន័យក្នុងអត្ថបទដែលជាទូទៅត្រូវបានគេហៅថា អានដើម្បីរៀន (Alfassi, 2004)។ ដោយឡែក ដើម្បីអនុវត្តអំណានយល់ន័យ យើងប្រទះឃើញថានៅតាមបណ្តាលប្រទេសអភិវឌ្ឍន៍មួយចំនួន ដូចជា សហរដ្ឋអាមេរិក អង់គ្លេស សង្ហបុរី គ្រូបង្រៀនបានប្រើប្រាស់សកម្មភាពផ្សេងៗសម្បូរបែប ក្នុងនោះកំណត់ត្រាអំណាន (Reading Logs) មកអនុវត្តក្នុងបំណិនអានផងដែរ (Wu, Valcke, & Keer, 2019; Lyutaya, 2011; Pak & Weseley, 2012)។ កំណត់ត្រាអំណាន ជាសកម្មភាពមួយដែលផ្តល់ឱកាសឱ្យសិស្ស ជ្រើសរើសប្រធានបទអំណានដែលពួកគេចូលចិត្ត មកអានដូចជា វិទ្យាសាស្ត្រ ប្រវត្តិសាស្ត្រ អក្សរសិល្ប៍ កំសាន្ត ឬអត្ថបទបែបប្រឌិតស្រមើលស្រមៃជាដើម (Ferlazzo, 2023)។ ពួកគេអានអត្ថបទទាំងនោះ រួចធ្វើការឆ្លុះបញ្ចាំង ឡើងវិញដោយការសរសេរ និងធ្វើបទបង្ហាញទៅកាន់គ្រូ ឬ មិត្តភក្តិ (Khonamri & Farzanegan, 2016)។ តាមរយៈដំណើរការក្នុងកំណត់ត្រាអំណាននេះ មានសកម្មភាពដែលជួយទាំងគ្រូ ទាំងសិស្សប្រមូលរបាយការណ៍កាន់តែងាយស្រួល ជាពិសេសអភិវឌ្ឍការអាន (Lyutaya, 2011)។ មិនតែប៉ុណ្ណោះ ពេលខ្លះសិស្សជួបបញ្ហាក៏ពួកគេទទួលបានអត្ថប្រយោជន៍ជាច្រើនពីកំណត់ត្រាអំណាននេះផងដែរ (Mansor, Adnan, & Abdullah, 2019)។ យោងទៅតាមការស្រាវជ្រាវពី Lyutaya (2011) លើកឡើងថា ការអនុវត្តសកម្មភាពកំណត់ត្រាអំណាន បានជួយដល់សិស្សក្នុងការឆ្លុះបញ្ចាំងនូវព័ត៌មានដែលពួកគេទទួលបានពីអត្ថបទទៅនឹងចំណេះដឹងដែរពួកគេមាន ទាក់ទងនឹងអត្ថបទមុនពេលអាន។ លើសពីនេះទៀត តាមរយៈការកត់ត្រាជាប្រចាំ សិស្សក៏អាចពង្រឹងបន្ថែមនូវជំនាញមួយផ្សេងទៀត គឺសំណេរ (Kalsum, Rauf, & Sardi, 2023)។ តាមរយៈសំណេរ សិស្សចេះធ្វើអន្តរកម្មនៃព័ត៌មានដែលមកពីប្រភពផ្សេងៗ ចេះរៀបចំ និងប្រមូលគំនិតរបស់ពួកគេឱ្យមានសណ្តាប់ធ្នាប់ ផ្តល់ឱកាសឱ្យសិស្សបង្ហាញគំនិត បង្កើនចំណេះដឹងបន្ថែមដែលមានស្រាប់ សួរសំណួរ និងជាពិសេសទៀតនោះ ជួយអភិវឌ្ឍដល់បំណិនសំណេរទៀតផង (Lyutaya, 2011)។ ដោយហេតុថាវាមានសារៈសំខាន់ចំពោះសិស្ស សកម្មភាពនេះត្រូវបានបណ្តាលប្រទេសជាច្រើនយកមកអនុវត្ត។ ដោយឡែក នៅប្រទេសកម្ពុជាផ្ទាល់ មិនទាន់ប្រទះឃើញមានភាពសប្បុរបែបក្នុងការអនុវត្តសកម្មភាពនេះនៅបឋមសិក្សាឡើយទេ។

ម្យ៉ាងវិញទៀត លទ្ធផលនៃការសិក្សានៅបឋមសិក្សាមានកម្រិតទាប។ តាមរយៈតេស្តថ្នាក់អន្តរជាតិ សម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ លទ្ធផលនៃតេស្តPISA-D បានបង្ហាញឱ្យឃើញថានៅប្រទេសកម្ពុជា សមត្ថភាពអំណានរបស់សិស្សទទួលបាន៣២១ពិន្ទុ គឺទាបជាងមធ្យមភាគ346ពិន្ទុ) (MoEYS,

2018)។ ដូចគ្នានេះដែរ ការអានហាក់ដូចជាពុំទាន់លេចធ្លោក្នុងចំណោមមុខវិជ្ជាទាំងបី(គណិតវិទ្យា វិទ្យាសាស្ត្រ អំណាន)នៅឡើយទេ (MoEYS, 2018)។ លទ្ធផលតេស្ត PISA-D ក៏បានបង្ហាញផងដែរ នៅក្នុងបណ្តាប្រទេសដែលបានចូលរួម ពិសេសប្រទេសនៅតំបន់អាស៊ាន ការអនុវត្តគណិតវិទ្យា និងវិទ្យាសាស្ត្រមានលទ្ធផលខ្ពស់ មានទំនាក់ទំនងដែលបានផ្សារភ្ជាប់យ៉ាងខ្លាំងជាមួយប្រសិទ្ធភាពខ្ពស់ក្នុងការអាន។ ព្រឹត្តិការណ៍ទាំងនេះ ឆ្លុះបញ្ចាំងថា ការកែលម្អអក្ខរកម្មការអានលើសិស្ស គឺជាគន្លឹះនៃការអនុវត្តរបស់សិស្សនៅក្នុងមុខវិជ្ជាផ្សេងទៀតឱ្យប្រសើរ (McNamara & Hayden, 2022)។

បំពោះលោកគ្រូអ្នកគ្រូនៅតាមសាលាបំណោះទូទៅវិញ ការប្រើកំណត់ត្រាអំណាននេះ ទៅក្នុងអំណានក៏ពុំសូវសង្កេតឃើញមានអនុវត្តដែរ។ បំពោះសិស្សានុសិស្សនៅបឋមសិក្សាកម្រិតខ្ពស់វិញ បើទោះបីពួកគេចេះអានបានស្ទាត់ តែបំពោះកាសិក្សាអត្ថបទអំណានតែក្នុងសៀវភៅសិក្សាគោល គឺមិនអាចបំពេញនូវតម្រូវការ និងចំណាងចំណូលចិត្តរបស់សិស្សគ្រប់ៗគ្នាបានឡោះទេ ដោយហេតុថាសិស្សខ្លះចូលចិត្តអត្ថបទបែបវិទ្យាសាស្ត្រ ខ្លះចូលចិត្តបែបអក្សរសិល្ប៍ឬ បែបឆ្នៃប្រឌិត ជាដើម(Ro, 2016)។ មួយវិញទៀត តាមរយៈការសិក្សាជាច្រើន (Clements, 2023b; McClure & Fullerton, 2017; Valencia, 2014) សិស្សមួយចំនួនអាចនឹងមិនចាប់អារម្មណ៍នឹងអត្ថបទក្នុងសៀវភៅសិក្សាគោលឬមិនអាន ដែលធ្វើឱ្យពួកគេមិនចង់ចំណាយពេលក្រៅម៉ោងសិក្សាអានអត្ថបទបន្ថែមដោយខ្លួនឯងឡោះទេ។ ដូចនេះ ពួកគេក៏ពុំសូវទទួលបានឱកាសអភិវឌ្ឍបំណិនអំណាន និងការអានយល់ន័យដែរ។

ដូចនេះដើម្បីជំរុញឱ្យកុមារកម្ពុជាមានទម្លាប់ក្នុងការអាន និងផ្តល់ឱកាសឱ្យពួកគេអភិវឌ្ឍបំណិនអាន តាមរយៈ សកម្មភាពកំណត់ត្រាអំណាន គឺមានភាពសក្តិសមដែលអាចឱ្យលោកគ្រូអ្នកគ្រូអនុវត្តលើសិស្សបាន។ ដោយហេតុថា នៅតាមបណ្តាលប្រទេសដែលវិស័យអប់រំមានភាពរីកចម្រើន សកម្មភាពកំណត់ត្រាអំណាននេះត្រូវបានអនុវត្តនិងទទួលបានប្រសិទ្ធភាពគួរជាទីកត់សម្គាល់ (Kalsum et al., 2023; Khonamri & Farzanegan, 2016; McClure & Fullerton, 2017) ប្រសិនបើយើងដាក់បញ្ចូលកម្មភាពនេះក្នុងកម្មវិធីសិក្សា កុមារអាចនឹងទទួលបានលទ្ធផលលើសពីការរៀនតែតាមសៀវភៅសិក្សាគោល។ ជាមួយគ្នានេះដែរ ការសិក្សាដោយប្រើវិធីកំណត់ត្រាអំណាននេះ នៅពុំទាន់មានការសិក្សាជាក់លាក់នៅឡើយក្នុងបរិបទកម្ពុជា ពិសេសនៅកម្រិតបឋមសិក្សា។ ដូចនេះការស្រាវជ្រាវនេះនឹងផ្តោតទៅលើការបង្រៀនដោយប្រើវិធីសាស្ត្រ កំណត់ត្រាអំណាន ដើម្បីជំរុញការអានយល់ន័យព្រមទាំងស្វែងយល់ពីទស្សនៈរបស់សិស្សបឋមសិក្សាថ្នាក់ទី៦ផងដែរ។

ការសិក្សានេះផ្តោតទៅលើសំណួរស្រាវជ្រាវដូចខាងក្រោម៖

- តើមានភាពខុសគ្នាទេនៃលទ្ធផលសិក្សារបស់សិស្ស នៅមុននិងក្រោយការប្រើ វិធីបង្រៀនកំណត់ត្រាអំណាន?
- តើវិធីបង្រៀនកំណត់ត្រាអំណាន មានប្រសិទ្ធភាពក្នុងការជំរុញការអានយល់ន័យរបស់សិស្សកម្រិតណា?
- តើសិស្សមានទស្សនៈយល់ឃើញយ៉ាងដូចម្តេចអំពីការប្រើវិធីសាស្ត្រកំណត់ត្រាអំណាននេះ?

១.១ វិធីកំណត់ត្រាអំណាន

វិធីកំណត់ត្រាអំណាន (Reading Log strategy)ជាការកត់ត្រាអ្វីដែលបានអានអ្វីដែលបានយល់ អ្វីដែលឆ្លុះបញ្ចាំងពីការយល់បន្ទាប់ពីអានចូលក្នុងកំណត់ត្រា (Wilhelm, 2021)។ បំណែកលោក Pak and Weseley (2012)បានលើកឡើងថា កំណត់ត្រាអំណានជាការបម្រើជាការរំលឹកដល់ឱ្យគ្រប់គ្នាជាសិស្សគួរអាន ប៉ុន្តែវាក៏ជាកំណត់ត្រានៃអ្វីដែលពួកគេបានអានផងដែរ។ លោក Pak & Weseley (2012) ក៏បានបន្ថែមទៀតថា សៀវភៅកត់ត្រាអាចប្រើដើម្បីបង្ហាញសិស្សនូវចំណងជើងសៀវភៅជាច្រើនដែលពួកគេបានអាន ហើយលើកទឹកចិត្តពួកគេឱ្យបន្តអាននិងកត់ត្រា។ កំណត់ហេតុការអាន ច្រើនតែប្រើសម្រាប់កត់ត្រានៅក្នុងការអានតាមការណែនាំផង និងការអានតាមផ្ទះផង ដើម្បីឱ្យឪពុកម្តាយ និងគ្រូអាចតាមដានការអានដែលសិស្សយកមកផ្ទះ។ កំណត់ត្រានេះក៏ជួយសិស្ស មិនឱ្យយកសៀវភៅដដែល មកពីផ្ទះច្រើនដងពេក។ លោក Mansor et al. (2019)យល់ថាកំណត់ត្រាអំណាន ជាវិធីជំរុញទៅដល់អ្នកអានគ្រប់រូប ធ្វើការឆ្លុះបញ្ចាំងពីអ្វីដែលពួកគេបានអាន។ បំពោះគ្រូបង្រៀនវិញជាធម្មតាតែងប្រើជារបាយការណ៍ ឬការហៅសួរផ្ទាល់ ឬការរាយការណ៍ក្នុងថ្នាក់សម្រាប់ប្រមូលកិច្ចការអំណានរបស់សិស្ស (Reading Eggs, 2023)។

ការសិក្សារៀនសូត្រអំណាន បានក្លាយជាវិធីមួយដែលអ្នកសិក្សាស្រាវជ្រាវគ្រប់រូបយកទៅប្រើប្រាស់មិនអាចខ្វះបាន។ ដោយឡែក ការគ្រប់គ្រងបាននូវទិន្នន័យដែលបានអាន បានក្លាយជាបញ្ហាចម្បងមួយដែលអ្នកអាន តែងជួបប្រទះគ្រប់ៗគ្នា (Ren, Uosaki, Kumamoto, Liu, & Yin, 2017)។ យើងឃើញថា ការអានតែមួយមុខ ក៏មិនអាចឱ្យអ្នកអាន ពិនិត្យនិងឆ្លុះបញ្ចាំងបានគ្រប់ជ្រុងជ្រោយនោះដែរ (Koumachi, 2020)។ ដើម្បីឆ្លើយតបជាមួយបញ្ហាខាងលើនេះ វិធីកំណត់ត្រាអំណាន បានរួមចំណែកយ៉ាងធំក្នុងការអានយល់ន័យ (Diptoadi, 2019)។ បំពោះការបង្រៀនវិញ កំណត់ត្រាអំណាន ត្រូវបានដាក់ឱ្យប្រើប្រាស់ ដើម្បីឱ្យគ្រូបង្រៀនអាចគាំទ្រសិស្សក្នុងការឆ្លុះបញ្ចាំងការអានរបស់ពួកគេ (Ren et al., 2017)។ ការធ្វើកំណត់ត្រាអំណាន បានក្លាយជាផ្នែកមួយនៃការបន្ថែមល្បឿននៃការអានយល់ន័យ ព្រោះសិស្សមិនត្រឹមតែអានប៉ុណ្ណោះទេ សិស្សក៏ធ្វើការឆ្លុះបញ្ចាំងជារឿយៗផងដែរ។ ដោយលើផ្នែកការយល់ដឹង ជំនាញ ឬយុទ្ធសាស្ត្រក្នុងពេលតែមួយបាន។ កំណត់ត្រានីមួយៗណែនាំឱ្យកុមារអាន រួចសរសេរចំណងជើងសៀវភៅ ព្រមទាំងសរសេរ គូសរូប ឆ្លុះបញ្ចាំង ឬកត់ត្រាអ្វីមួយដែលទាក់ទងនឹងការផ្តោតអារម្មណ៍របស់សិស្សតាមសប្តាហ៍នីមួយៗ (Decarbo, 2023)។ យោងទៅតាម Decarbo (2023) ការដោះដូរកំណត់ត្រាអំណាន បានផ្តល់ឱកាសឱ្យសិស្សពង្រីកចំណេះដឹង ពីព្រោះកំណត់ត្រាអំណាន ប្រៀបដូចជាការមានទិន្នន័យដែលបានអាននៅក្នុងដៃ ហើយអាចធ្វើការដោះដូរជាមួយសិស្សដទៃ ទាក់ទងនឹងអ្វីដែលសិស្សម្នាក់ៗមាន។ កំណត់ត្រាអំណាននេះធ្វើឱ្យសិស្សមានទំនួលខុសត្រូវ និងដឹងនូវអ្វីដែលសិស្សបាន កំពុង នឹងធ្វើ តាមរយៈការប្រើប្រាស់កំណត់ត្រានោះ (Yanto, Saefullah, & Kwary, 2020)។ កំណត់ត្រាអំណាន ត្រូវបានបង្កើតឡើងជាឧបករណ៍ដែលគ្រូ និងឪពុកម្តាយអាចប្រើ ដើម្បីប្រាកដថាសិស្សបានបញ្ចប់ការអានប្រចាំថ្ងៃរបស់ពួកគេ។ ដោយវាជា

វិធីសាស្ត្រជំរុញទៅដល់អ្នកអានគ្រប់រូបឱ្យឆ្លុះបញ្ចាំងពីអ្វីដែលពួកគេបានអាន (Ferlazzo, 2023)។ ចំពោះគ្រូបង្រៀនវិញ ជាធម្មតាតែងប្រើជារបាយការណ៍ ឬ ការហៅសួរផ្ទាល់ ឬការរាយការណ៍ក្នុងថ្នាក់ សម្រាប់ប្រមូលកិច្ចការអំណានរបស់សិស្ស។ ចំពោះវិធីសាស្ត្រខាងលើនេះតែងមានការពេញនិយម និងអនុវត្តក្នុងន័យបង្កើនទម្លាប់ការសិក្សាស្រាវជ្រាវរបស់កុមារលើប្រធានបទដែលពួកគេចង់ដឹង និងការអភិវឌ្ឍបំណិនអានរបស់ពួកគេឱ្យកាន់តែប្រសើរឡើង (Dorasamy, 2017; Yanto et al., 2020)។ វិធីកំណត់ត្រាអំណានបានរួមចំណែកក្នុងវិស័យអំណាន និងការអានយល់ន័យក៏ដូចជាបានផ្តល់ឱកាសឱ្យសិស្សឆ្លុះបញ្ចាំងនូវខ្លឹមសារ និងការត្រួតពិនិត្យរាល់ការរីកចម្រើននៃការអានរបស់ខ្លួនរួមទាំងជួយឱ្យពួកគេកាន់តែមានកម្លាំងចិត្តក្នុងការអានទៀតផង។ កំណត់ត្រាអំណានបានដើរតួរនាទីសំខាន់ទន្ទឹមនឹងការរៀនដើម្បីអាន។ វាបានបានជំរុញឱ្យសិស្សអានអត្ថបទផ្សេងៗដែលបើកទូលាយនូវពហុប្រធានបទ និងខ្លឹមសារ ដែលនិងជួយអភិវឌ្ឍការត្រិះរិះពិចារណា និងការគិតបានស៊ីជម្រៅតាមរយៈព័ត៌មានដែលទទួលបានពីការអាននិងការកត់ត្រាឆ្លុះបញ្ចាំង។ បន្ថែមលើនេះទៀត សិស្សនឹងបង្កើតទម្លាប់អានកត់ត្រា និងស្រាវជ្រាវដែលក្លាយជាផ្នែកមួយនៃការសិក្សាពេញមួយជីវិតហើយចូលរួមឱ្យពួកគេក្លាយជាពលរដ្ឋល្អ។

១.២ ដំណាក់កាលនៃកំណត់ត្រាអំណាន

កំណត់ត្រាអំណានជាតិចនិកមួយដែលផ្អែកលើទ្រឹស្តីអ្នកអាននិងការឆ្លើយតប (Reader-response Theory)។ ទ្រឹស្តី អ្នកអាន និង ឆ្លើយតបគឺជាទ្រឹស្តីអក្សរសាស្ត្រដែលសង្កត់ធ្ងន់លើតួនាទីរបស់អ្នកអានក្នុងការបង្កើតអត្ថន័យនៃអត្ថបទ(Holland, 1989)។

ជាតុដែលគួរតែត្រូវបានសរសេរនៅលើគម្រោងកំណត់ហេតុការអានរបស់ពួកគេគ្របដណ្តប់លើប្រាំមួយផ្នែក គឺ៖

(1) បំណងជើងនៃអត្ថបទនីមួយៗដែលពួកគេអាន ដើម្បីបំពេញព័ត៌មាន

(2) ប្រភេទនៃអត្ថបទនីមួយៗដែលពួកគេ អាន

(3) ប្រភពនៃអត្ថបទនីមួយៗដែលពួកគេអាន

(4) មូលហេតុនៃអត្ថបទនីមួយៗ គួរឱ្យចាប់អារម្មណ៍ក្នុងការអាន

(5) ការឆ្លុះបញ្ចាំងពីអ្វីដែលបានរកឃើញនៅពេលកំពុងអាន កំណត់គោលបំណង និងទស្សនៈរបស់អ្នកនិពន្ធលើអត្ថបទនីមួយៗ និង

(6) សេចក្តីសង្ខេបខ្លីៗនៃអត្ថបទនីមួយៗ។

១.៣ ការអានយល់ន័យ

ការអានយល់ន័យ គឺជាសមត្ថភាពក្នុងការអានអត្ថបទ និងយល់ពីអត្ថន័យរបស់វាយ៉ាងស៊ីជម្រៅ(Snow, 2002)។ នេះរួមបញ្ចូលទាំងលទ្ធភាពក្នុងការកំណត់គំនិតសំខាន់ៗ និងព័ត៌មានលម្អិតនៃអត្ថបទ, ធ្វើការសន្និដ្ឋានអំពីអត្ថបទ ដូចជាគោលបំណងរបស់អ្នកនិពន្ធ ឬអ្វីដែលតួអង្គកំពុងគិត ឬមានអារម្មណ៍, ភ្ជាប់អត្ថបទទៅនឹងចំណេះដឹង និងបទពិសោធផ្ទាល់ខ្លួនរបស់អ្នក(Alexander, 2005),

វាយតម្លៃអត្ថបទ ដូចជាភាពត្រឹមត្រូវ ភាពពាក់ព័ន្ធ និងការបញ្ចុះបញ្ចូលរបស់វានិងសង្ខេបអត្ថបទដោយ ពាក្យផ្ទាល់ខ្លួនរបស់អ្នក (Kintsch, 1988)។

ការអានយល់ន័យពឹងផ្អែកលើសមត្ថភាពពីរដែលទាក់ទងគ្នា៖ ការអានពាក្យ (អាចបកស្រាយនិមិត្តសញ្ញានៅលើទំព័រ) និងការយល់ភាសា (អាចយល់អត្ថន័យនៃពាក្យ និងប្រយោគ) (Spencer & Wagner, 2018)។ ការអានពិតប្រាកដ ទាក់ទងនឹងការគិត ការរៀន និងការពង្រីកចំណេះដឹង និងការយល់ដឹងរបស់អ្នកអាន (Madjdi & Nurcahyo, 2020)។ វាទាក់ទងនឹងការកសាងចំណេះដឹងពីអតីតកាលការស្មាត់ ជំនាញព័ត៌មានថ្មីៗនិងការភ្ជាប់ជាមួយនឹងគំនិតរបស់អ្នកដែលអ្នកមិនធ្លាប់បានជួប (Perfetti & Stafura, 2014)។

ការអានយល់ន័យបានល្អគឺមានសារៈសំខាន់ ប្រសិនបើអ្នកអានមានគោលបំណងអានចង់រៀនពីអត្ថបទមួយ និងអ្នកអានចង់រីករាយនឹងអ្វីដែលពួកគេកំពុងអាន (Palopo, 2019)។ ការត្រួតពិនិត្យស្ថិតិទ្រង់ទ្រាយធំនៃការសិក្សាស្រាវជ្រាវផ្សេងគ្នាបានរកឃើញថាចំនួនពេលវេលាទំនេរដែលកុមារបានចំណាយក្នុងការអាន ឬកំពុងអានគឺជាសកម្មភាពដ៏មានអានុភាពនៃការអានយល់ន័យ (និងជំនាញអក្ខរកម្មសំខាន់ៗផ្សេងទៀតដូចជា ការទទួលស្គាល់ពាក្យ អក្ខរាវិរុទ្ធ និងជំនាញវាក្យសព្ទ) Clements (2023a); (Decarbo, 2023; Mansor et al., 2019)។ ការអានដល់កុមារតូចៗ និងជួយពួកគេឱ្យអភិវឌ្ឍអាកប្បកិរិយាវិជ្ជមាន ចំពោះការអានអាចបង្កើតទម្លាប់ដែលអាចឱ្យពួកគេអភិវឌ្ឍជំនាញទាក់ទងនឹងអក្ខរកម្ម និងទទួលបានចំណេះដឹងពេញមួយជីវិតរបស់ពួកគេ(Alfassi, 2004)។

ការអានយល់ន័យទាមទារនូវចំណេះដឹង និងជំនាញផ្សេងៗគ្នា៖ វាក្យសព្ទ និងចំណេះដឹងផ្ទៃខាងក្រោយ, ការរួមបញ្ចូលនិងជំនាញសន្និដ្ឋាន, ការយល់ដឹងអំពីរចនាសម្ព័ន្ធ/ទំនាក់ទំនងភាសា និងចំណេះដឹង និងការប្រើប្រាស់រចនាសម្ព័ន្ធអត្ថបទ(Clements, 2023b)។ ការត្រួតពិនិត្យការអានយល់ន័យ ត្រូវបានសរសេរឡើងដើម្បីគាំទ្រដល់សាលារៀនក្នុងការបង្រៀនការអានយល់ន័យ ប្រកបដោយប្រសិទ្ធភាពតាមដែលអាចធ្វើទៅបាន (Ferlazzo, 2023)។ ជំហានទី១នៃវិធីនេះ នឹងជួយអ្នកក្នុងការត្រួតពិនិត្យការផ្តល់បច្ចុប្បន្នរបស់អ្នកសម្រាប់ការបង្រៀនការយល់ដឹង ហើយជំហានទី២ នឹងគាំទ្រអ្នកនៅពេលអ្នកបង្កើតផែនការយុទ្ធសាស្ត្រដើម្បីកែលម្អការផ្តល់។ ជំហានទី៣នៃវិធីនេះ គឺពោរពេញដោយធនធាន គំនិត និងករណីសិក្សាដែលផ្តល់ឧទាហរណ៍នៃវិធីសាស្ត្រដ៏មានប្រសិទ្ធភាពដែលប្រើប្រាស់ដោយសាលារៀនពិតប្រាកដ (Clements, 2023a; Decarbo, 2023)។

កំណត់ត្រាអំណាន ជាសម្មភាពទូទៅដែរជាធម្មតាប្រើប្រាស់សម្រាប់អ្នកអានក្នុងការឆ្លុះបញ្ចាំងលទ្ធផលអំណានរបស់គេ។ ការអនុវត្ត កំណត់ហេតុអំណានចំពោះក្មេងៗ នៅបឋមសិក្សាមានសារៈប្រយោជន៍ជាច្រើនដែលជាទីគួរកត់សម្គាល់។ ចំពោះដំណើរការនៃកំណត់ហេតុអំណានមានដូចតទៅ៖

ជំហានទី១ ការជ្រើសរើសប្រធានបទអាន

គ្រូជាអ្នកផ្តល់សិស្សនូវសម្ភារអំណានដែលមានភាពសម្បូរបែប និងមានច្រើនជម្រើសដូចជាអត្ថបទប្រវត្តិសាស្ត្រ វិទ្យាសាស្ត្រ អក្សរសិល្ប៍ កម្សាន្ត ជាដើម។ ឯសិស្សត្រូវជ្រើសរើសអត្ថបទដោយខ្លួន

ឯងសម្រាប់អានដោយពួកគេគឺមិនត្រូវបានតម្រូវឬកំណត់ឱ្យអានអត្ថបទជាក់លាក់នោះទេ។ ពួកគេមានភាពឯករាជ្យក្នុងអំណានដោយមិនត្រូវថាត្រូវអានតាមកម្រិតថ្នាក់របស់គេឡើយ មិនថាអានអត្ថបទដែលខ្ពស់ឬទាបជាងថ្នាក់របស់ខ្លួន។ ចំពោះករណីសិស្សអានសៀវភៅក្រៅឬអត្ថបទក្រៅពីការផ្តល់ជូនរបស់គ្រូនោះ ពួកគេក៏អាចជ្រើសអានបែបនេះផងដែរនិយាយរួមគឺមិនមានការកំណត់ថាត្រូវតែជ្រើសមួយណាជាជាប់ខាតនោះទេ។

ជំហានទី២ ដំណើរការអំណាន

ក្នុងជំហាននេះសិស្សបានជ្រើសរើសអត្ថបទអំណានរបស់គេរួចហើយ។ ការអនុវត្តអំណានគឺមិនបានកំណត់ឱ្យសិស្សត្រូវបញ្ចប់អត្ថបទអំណានណាមួយមុននោះទេ គឺពួកគេជាអ្នកសម្រេចដោយខ្លួនឯងថានឹងអានមួយណាមុន។ ការធ្វើបែបនេះសិស្សគឺមានសម្ពាធដែលជាហេតុធ្វើឱ្យសកម្មភាពកាន់តែមានភាពរីករាយនិង មិនគួរធុញទ្រាន់។ ចំពោះពេលវេលានោះគឺសិស្សត្រូវបញ្ចប់២ ទៅ៣អត្ថបទក្នុងមួយសប្តាហ៍។ ចំណែកឯវិធីសាស្ត្រវិញពួកគេអាចអានតាមតែតម្រូវការរបស់គេ ដោយពួកគេអាចអានតាមប្រពន្ធ័អេឡិទ្រនិច ឬសៀវភៅ ឬអត្ថបទកាសែតឬទស្សនាវដ្តីជាដើម។

ជំហានទី៣ ការកត់ត្រាកំណត់ហេតុអំណាន

សិស្ស នៅក្នុងដំណាកកាលនេះ ពួកគេត្រូវប្រើកំណត់ហេតុ មកតក់ត្រានូវអ្វីដែលគេបានអានក្នុងកំណត់ត្រានេះគួរមាន៖

១. ឈ្មោះសៀវភៅ និងទំព័រនិងពេលវេលាដែលគេបានចំណាយអាន

២. ក្នុងកំណត់ត្រាគួរមានការឆ្លើយតបនឹងសំណួរដូចខាងក្រោម៖

តើអត្ថបទមានគំនិតសំខាន់អ្វីខ្លះ?

តើអ្នកបានរៀនសូត្រអ្វីពីការអាន?

តើអ្នកមានសំណួរឬចំងល់អ្វីបន្ទាប់ពីអានរួច?

ជំហានទី៤ ការធ្វើបទបង្ហាញនិងចែកផ្សាយ

ដោយសិស្សបានតក់ត្រានិងឆ្លុះបញ្ចាំងនូវអ្វីដែលពួកគេបានអានចូលក្នុងកំណត់ហេតុអំណានរួចមក ពួកគេត្រូវធ្វើបទបង្ហាញក្នុងថ្នាក់ឬធ្វើការដោះដូរកំណត់ហេតុអានរបស់គេ ជាមួយអ្នកផ្សេងទៀតឬធ្វើការបង្ហាញកំណត់ហេតុរបស់គេទៅកាន់គ្នាទៅវិញទៅមក ចែកផ្សាយកំណត់ហេតុគ្នា។

១.៣ កំណត់ត្រាអំណាន និងការអានយល់ន័យ

ការសរសេរក្នុងកំណត់ហេតុនៃការអានត្រូវបានគេគិតថា វាមានប្រយោជន៍ប្រើនជាង(ដែលវាជាសម្ភារៈជំនួយក្នុងការរៀនសូត្រ)ជាជាងការពន្លេច គូសបន្ទាត់ពីក្រោម ឬសង្ខេប ព្រោះវាអនុញ្ញាតឱ្យមានការផ្ទុក ព័ត៌មានដោយខ្លួនឯងអំពីខ្លឹមសារ និងបានជំរុញ សិស្សឱ្យគិតកាន់តែស៊ីជម្រៅអំពីអ្វីដែលពួកគេអាន។ ខណៈពេលដែលការវាយតម្លៃការយល់ដឹងមិនត្រូវបានផ្តល់ឱ្យវាច្បាស់ណាស់ថាការអានកំណត់ត្រា ត្រូវបានលើកកម្ពស់ការយល់ដឹងកាន់តែស៊ីជម្រៅអំពីព័ត៌មានវិទ្យាសាស្ត្រដែលត្រូវបានអាន(Kalman, 2011)។ តាម Currier (2013) លោកបានបង្ហាញថាកំណត់ត្រាអំណាន និងការអាន

យល់ន័យមានទំនាក់ទំនងគ្នា ដោយសារកំណត់ត្រាអំណានធ្វើឱ្យការអានយល់ន័យរបស់សិស្សមានការកើនឡើង។ លោកបានបន្តទៀតថា *"បើយើងក្រឡេកមើលកំណត់ត្រាអំណានរបស់សិស្ស គឺសិស្សអាចបង្ហាញបានន្យូវគំនិត និងការប្រើវាក្យសព្ទបានប្រសើរបន្ថែមទៀត។មិនតែប៉ុណ្ណោះ ឥរិយាបថរបស់សិស្សក៏កាន់តែមានជំនឿចិត្តក្នុងការយល់ន័យនៃអត្ថបទផ្សេងៗបានផងដែរ(ទំព័រ12)។"* ជាមួយគ្នានេះដែរ (Rakana, 2017) ក៏បានរកឃើញផងដែរថា ការពង្រឹងការយល់ដឹង និងភាពពេញចិត្តរបស់សិស្សទៅអត្ថបទអក្សរសោស្ត្រ កាន់តែប្រសើរឡើងនៅពេលសិស្សមានទម្លាប់អានដោយប្រើកំណត់ត្រាអំណាននេះ។ ម្យ៉ាងទៀត សិស្សដែលមានប្រវត្តិចំណេះដឹងខ្លាំងហើយ ក៏កាន់តែអាចពង្រីកសមត្ថភាពភាសារបស់គេ កាន់តែប្រសើរជាងមុន។

២. វិធីសាស្ត្រនៃការស្រាវជ្រាវ

ការស្រាវជ្រាវនេះផ្តោតលើមុខវិជ្ជាភាសាខ្មែរផ្នែកអំណាន ដោយប្រើវិធីស្រាវជ្រាវតាមបរិមាណវិស័យ(ពិសោធន៍) និងគុណវិស័យ (សម្ភាសន៍ទស្សន:យល់ឃើញក្រោយពីឆ្លងកាត់ការអនុវត្តវិធីកំណត់ត្រាអំណាន)។ មុខវិជ្ជាភាសាខ្មែរសម្រាប់ថ្នាក់ទី៦នេះ ជាផ្នែកមួយដ៏សំខាន់សម្រាប់សិស្សក្នុងការបន្តការសិក្សានៅមធ្យមសិក្សាបឋមភូមិ។ សិស្សថ្នាក់ទី៦នេះ ជាសំណាកសំខាន់ក្នុងការសិក្សាស្រាវជ្រាវនេះ។ សិស្សសរុបនៃថ្នាក់ទី៦មាន១២ថ្នាក់ដែលមានសិស្សសរុប៤២១នាក់ ស្រី២២៨នាក់។ ឯសំណាកក្នុងការស្រាវជ្រាវនេះ ត្រូវបានជ្រើសយក២ថ្នាក់ គឺថ្នាក់ទី៦មួយថ្នាក់ ប្រើសម្រាប់ពិសោធវិធីសាស្ត្រ និងថ្នាក់ទី៦ មួយថ្នាក់ទៀត ប្រើជាថ្នាក់ត្រួតពិនិត្យ ឬថ្នាក់ប្រៀបធៀប។ គំរូសំណាកសរុបមានចំនួន៧១នាក់(ដែលក្នុងនោះសិស្សប្រុសមានចំនួន៣៥ សិស្សស្រីមានចំនួន៣៦នាក់)។ ការជ្រើសរើសថ្នាក់ពិសោធ ធ្វើឡើងតាមការចាត់តាំង និងថ្នាក់ប្រៀបធៀប ធ្វើឡើងតាមរយៈការស្នើសុំ។ ថ្នាក់ពិសោធមាន N= ៣៩ ថ្នាក់ប្រៀបធៀបមាន N=៣២។ ថ្នាក់ទី៦ទាំងពីរថ្នាក់នេះ មិនធ្លាប់ឆ្លងកាត់វិធីបង្រៀនតាមបែបកំណត់ត្រាអំណាននេះនៅឡើយទេ។ សិស្សនៅថ្នាក់ទី៦មានអាយុបន្លោះ១២ទៅ១៣ឆ្នាំដោយសាលាអនុវត្តទៅតាមព្រះរាជក្រឹត្យឆ្នាំ២00៧ (Royal-Decree, 2007)។ យោងតាមរបាយការណ៍គ្រូបន្ទុកថ្នាក់ទាំងពីរ របាយការណ៍នេះបង្ហាញថា កម្រិតជីវភាពសិស្សនៃថ្នាក់ទាំងពីមានលក្ខណៈប្រហាក់ប្រហែលគ្នាគឺ ថ្នាក់ពិសោធន៍ (សិស្សមានជីវភាពកម្រិតមធ្យមចំនួន៦៨.៥៦% និងសិស្សមានកម្រិតជីវភាពក្រីក្រមាន៣១.៤៤%) ឯថ្នាក់ធៀប (សិស្សមានកម្រិតជីវភាពមធ្យមចំនួន៧១.0៦% និងសិស្សមានកម្រិតជីវភាពក្រីក្រចំនួន២៨.៩៤%)។ ថ្នាក់ពិសោធ ដឹកនាំការបង្រៀនដោយអ្នកស្រាវជ្រាវផ្ទាល់ដែលបានទទួលការបណ្តុះបណ្តាល និងហ្វឹកហាត់វិធីសាស្ត្រនេះ ឯថ្នាក់ប្រៀបធៀបបង្រៀនដោយប្រើវិធីបែបប្រពៃណី។ សម្រាប់ការសម្ភាស សិស្សចំនួន៦នាក់ត្រូវបានជ្រើសរើសពីថ្នាក់ពិសោធដោយប្រើការជ្រើសរើសចៃដន្យធម្មតា(Simple random)។ ក្នុងការសិក្សានេះ សិស្សទាំង៦ត្រូវបានកំណត់ហៅសិស្សទី១ជា S1 សិស្សទី២ជា S2 សិស្សទី៣ជាS3 សិស្សទី៤ជា S4 សិស្សទី៥ជា S5 សិស្សទី៦ជា S6 ដែលត្រូវបានជ្រើសរើសតាមវិធីចៃដន្យធម្មតា(Simple random)។

២.១ ទីកន្លែងស្រាវជ្រាវ

ការស្រាវជ្រាវនេះបានប្រព្រឹត្តទៅនៅសាលាបឋមសិក្សាមួយក្នុងរាជធានីភ្នំពេញ។ សាលាបឋមសិក្សា មានផ្ទៃដី១ហិចតា៤៥អារ៥៨សង់ទីអារ ដោយមានទីចាត់ការ១ខ្នងនឹងមានអគារសិក្សាចំនួន៦ខ្នង។ ពីមួយឆ្នាំទៅមួយឆ្នាំសាលាមួយនេះមានកសាងហេដ្ឋានរចនាសម្ព័ន្ធនានាជាបន្តបន្ទាប់ដោយសារការសាមគ្គីគ្នារវាងគណៈគ្រប់គ្រង លោកគ្រូ អ្នកគ្រូ ព្រមទាំងមានការចូលរួមរបស់មាតាបិតារបស់សិស្សានុសិស្ស សប្បុរសជន អាជ្ញាធរមូលដ្ឋាន។ នៅក្នុងឆ្នាំ២០២៣នេះសាលាបានកសាងសមិទ្ធិផលជាប្រើនដូចជា ទី១រៀបចំកសាងថ្នាក់ មណ្ឌលសិក្សាឌីជីថលដែលបំពាក់ទៅដោយបច្ចេកទេសផ្នែកវិទ្យាសាស្ត្រ ភាសាអង់គ្លេស ភាសាបិន កុំព្យូទ័រចាប់ពីថ្នាក់ទី១ដល់ទី៦ បច្ចុប្បន្នសាលាបឋមសិក្សាសន្ធរម៉ុកមានបុគ្គលសិក្សាសរុបចំនួន១០២នាក់ស្រី៨៧នាក់ ដោយមាននាយកនិងនាយករង ចំនួន៤នាក់ស្រី១នាក់ គ្រូជំនាញ២៣នាក់ស្រី២០នាក់ គ្រូទទួលបន្ទុកថ្នាក់ចំនួន៧៥នាក់ស្រី៦៦នាក់។

ឧបករណ៍ប្រមូលទិន្នន័យ

ការសិក្សាស្រាវជ្រាវប្រើតាមវិធីសាស្ត្របន្សំរវាងបរិមាណវិស័យនិងគុណវិស័យ។ សម្រាប់ការប្រមូលទិន្នន័យបរិមាណវិស័យ នេះអ្នកស្រាវជ្រាវប្រើប្រាស់តេស្ត(បុរេតេស្ត និងតេស្តបញ្ចប់)សម្រាប់វាស់លទ្ធផលសិក្សារបស់សិស្ស ដែលឆ្លើយតបទៅនឹងសំណួរស្រាវជ្រាវទី១និងទី២។ ឯ សំណួរសម្ភាសន៍ទាក់ទងនឹងទស្សនៈយល់ឃើញរបស់សិស្សប្រើ ដើម្បីឆ្លើយតបទៅនឹងសំណួរស្រាវជ្រាវទី៣។ ចំពោះតេស្ត(បុរេតេស្ត និងតេស្តបញ្ចប់)ត្រូវជ្រើសចេញពីអត្ថបទទាំងឡាយដែលបានដាក់ឱ្យសិស្សអានដោយសេរី និង ផ្តោតទៅលើខ្លឹមសារនៃអត្ថបទដែលបានដាក់ឱ្យសិស្សអានមានដូចជា អត្ថបទដកស្រង់ទី១ មាន៥សំណួរពហុជ្រើសរើស អត្ថបទដកស្រង់ទី២ មាន៥សំណួរពហុជ្រើសរើស អត្ថបទដកស្រង់ទី៣ មាន៤សំណួរពហុជ្រើសរើស។ តេស្តលទ្ធផលសិក្សា ត្រូវបានបង្កើតឡើងដោយអ្នកស្រាវជ្រាវផ្ទាល់ព្រមទាំងមានការត្រួតពិនិត្យនិងកែសម្រួលដោយសហអ្នកនិពន្ធ និងគ្រូប្រចាំថ្នាក់ផងដែរ។ ក្រោយពិនិត្យដោយមើលឃើញថាកម្រងសំណួរតេស្តនេះមានភាពត្រឹមត្រូវ អាចទទួលយកបាន មុនយកទៅប្រើដើម្បីប្រមូលទិន្នន័យសាកល្បង។ តេស្តត្រូវបានយកទៅធ្វើការសាកល្បងនៅថ្នាក់ទី៦មួយទៀតដែលមិនមែនជាថ្នាក់ពិសោធនិងថ្នាក់ធៀបនោះទេ ដើម្បីពិនិត្យមើលគុណភាពនៃតេស្ត។ លទ្ធផលនៃការសាកល្បងតេស្តបង្ហាញថា Alpha α=0.66 មានន័យថា តេស្តនេះមានកម្រិតល្អអាចយកទៅប្រើប្រាស់បានក្នុងការប្រមូលទិន្នន័យបាន (Cohen, 1988)។ សំណួរសម្ភាសន៍ សម្រាប់សម្ភាសន៍សិស្សគឺត្រូវរៀបចំឡើងដោយដោយអ្នកស្រាវជ្រាវ ព្រមទាំងមានការចូលរួមពិភាក្សានិងត្រួតពិនិត្យកែសម្រួលជាមួយគ្រូឧទ្ទេសដឹកនាំ ដោយពិនិត្យមើលឃើញថាសំណួរសម្ភាសន៍នេះមានភាពត្រឹមត្រូវនិងសមស្របគោលបំណងស្រាវជ្រាវមុនយកទៅប្រើដើម្បីប្រមូលទិន្នន័យ។

២.២ វិធីសាស្ត្រប្រមូលទិន្នន័យ

ការប្រមូលទិន្នន័យត្រូវបានធ្វើឡើងនៅមុននិងក្រោយការបង្រៀនរយៈពេល១០សប្តាហ៍(ចាប់ផ្តើម២៦ខែកុម្ភៈ ឆ្នាំ២០២៣ ដល់ថ្ងៃទី០៤ ខែមេសា ឆ្នាំ២០២៣) ដោយប្រើវិធីបង្រៀនតាមបែប

កំណត់ត្រាអំណាន។ បុរេតេស្ត គឺធ្វើឡើងដើម្បីវាស់ស្ទង់ចំណេះដឹងមានស្រាប់របស់សិស្សនៅមុនពេលអនុវត្តវិធីសាស្ត្របង្រៀនតាមបែបកំណត់ត្រាអំណាន ដើម្បីប្រមូលទិន្នន័យទាក់ទងនិងលទ្ធផលសិក្សារបស់សិស្សនៃមុខវិជ្ជាភាសាខ្មែរ។ តេស្តបញ្ចប់គឺប្រើប្រាស់ក្រោយពេលអនុវត្តវិធីសាស្ត្របង្រៀនតាមបែបកំណត់ត្រាអំណាន ដើម្បីវាយតម្លៃលទ្ធផលសិក្សារបស់សិស្សនៃមុខវិជ្ជាភាសាខ្មែរ។ តេស្តទាំងពីលើក ដាក់ឱ្យសិស្សធ្វើរយៈពេល៤០នាទី។ បន្ទាប់មក តេស្តទាំងនោះ ត្រូវកែដោយអ្នកស្រាវជ្រាវផ្ទាល់។ ជាមួយគ្នានេះដែរ អ្នកស្រាវជ្រាវក៏បានធ្វើការសរុបការកត់ត្រាលើភាពរីកចម្រើនរបស់សិស្សចំនួន៥លើកផងដែរ ដោយយកតម្លៃមធ្យមរយៈពេល២សប្តាហ៍ម្តង គឺពិនិត្យលើកិច្ចការលើសិស្សថ្នាក់ពិសោធន៍ជាបុគ្គល។ សំណួរសម្ភាសន៍ គឺប្រើសម្រាប់សម្ភាសន៍សិស្ស ពីចំណាប់អារម្មណ៍របស់ពួកគេ នៅក្រោយពេលអនុវត្តវិធីសាស្ត្របង្រៀនបែបកំណត់ត្រាអំណាន។ ក្រោយពីការធ្វើតេស្តបញ្ចប់ ការសម្ភាស ធ្វើឡើងជាបុគ្គលដោយសម្ភាសក្នុងម្នាក់ ប្រើរយៈពេល១៥នាទីទៅ២០នាទី ហើយការសម្ភាសនេះបានស្នើសុំអ្នកផ្តល់បទសម្ភាសន៍ ឋតសំឡេង ដើម្បីជាជំនួនដល់ការកត់ត្រាសិក្សាបន្ត។

២.៣ ដំណើរការការបង្រៀន

ក្នុងការសិក្សានេះ ការប្រើបុរេតេស្តនិងតេស្តបញ្ចប់ទៅលើសិស្សថ្នាក់ទី៦នៃថ្នាក់ពិសោធន៍ និងថ្នាក់ត្រួតពិនិត្យ ដើម្បីពិនិត្យប្រសិទ្ធភាពនៃការប្រើវិធីសាស្ត្របែបកំណត់ត្រាអំណានទៅលើលទ្ធផលសិក្សា។ ការសិក្សានេះប្រើរយៈពេលដប់សប្តាហ៍ក្នុងអំឡុងពេលចុះកម្មសិក្សានៅចន្លោះថ្ងៃថ្ងៃទី២៦ខែកុម្ភៈ ឆ្នាំ២០២៣ ដល់ថ្ងៃទី០៤ ខែមេសា ឆ្នាំ២០២៣។

- *ការបង្រៀននៅថ្នាក់ពិសោធន៍*

ការសិក្សានេះបានអនុវត្តតាមដំហានដូចតទៅ៖ ជំហានដំបូង គ្រូពន្យល់និងផ្តល់សន្លឹកកិច្ចការសម្រាប់សិស្សស្រង់ព័ត៌មានដែលត្រូវអាន រួចគ្រូអនុញ្ញាតឱ្យសិស្សមានសេរីភាពក្នុងការរើសអត្ថបទអំណាន ដោយសិស្សជាអ្នកកំណត់ តែគ្រូបានផ្តល់អត្ថបទមកសិស្សដើម្បីជ្រើសរើសអាន។ បន្ទាប់មកសិស្សអានអត្ថបទអំណានដែលខ្លួនបានជ្រើសរើស ព្រមទាំងបំពេញក្នុងសន្លឹកកិច្ចការដែរដោទិន្នន័យផ្សេងៗក្នុងអំណាន។ បន្ទាប់មកទៀត សិស្សត្រូវចែកផ្សាយដល់សិស្សដទៃ ឬ គ្រូបង្រៀន។ គ្រូបង្រៀនឱ្យសិស្សអនុវត្តតាមវិធីនេះដដែលៗ នៅក្រោយមេរៀនភាសាខ្មែរនីមួយៗបានបញ្ចប់។ គ្រូក៏បានត្រួតពិនិត្យកិច្ចការបស់សិស្សជាប្រចាំផងដែរ ដោយផ្តល់យោបល់កែលម្អបែបស្ថាបនា។

- *ការបង្រៀននៅថ្នាក់ត្រួតពិនិត្យ*

នៅក្នុងថ្នាក់ត្រួតពិនិត្យ គ្រូវិធីបង្រៀនដែលគាត់ប្រើពីមុនមក។ វិធីសាស្ត្រនោះត្រូវបានហៅថាវិធីសាស្ត្របែបប្រពៃណី វិធីបង្រៀនបែបបាឋកថា។ គ្រូផ្តល់ការពន្យល់ដោយផ្ទាល់ គ្រូធ្វើសកម្មភាពប្រើនក្នុងការបង្រៀនពីមេរៀនមួយទៅមេរៀនមួយ។ សកម្មភាពរៀននៅក្នុងក្រុមត្រួតពិនិត្យរួមាន ការពន្យល់ ការសួរ ឆ្លើយ ការពិភាក្សាក្រុមនិងដៃគូរយៈពេលខ្លី ការធ្វើកិច្ចការជាបុគ្គល។ យុទ្ធវិធីបង្រៀនដទៃទៀតមាន ការកំណត់វត្ថុបំណងនៃការរៀន ពន្យល់កិច្ចការផ្ទះ ត្រួតពិនិត្យលទ្ធផលសិក្សា។

សិស្សទាំងអស់ ដាក់កំណត់ត្រាអំណាន បុងក្រោយរបស់ពួកគេនៅសប្តាហ៍ទី៩។ ឯកសារនៃកំណត់ត្រាអំណានរបស់សិស្សត្រូវបានវិភាគជាតារាង ដើម្បីមើលសិស្សភាគច្រើនចូលចិត្តលើសមាសធាតុនីមួយៗនៃកំណត់ត្រាអំណានបានប្រគល់ជូនគ្រូបង្រៀន។ កំណត់ត្រាអំណានជាបុគ្គល ត្រូវបានវាយតម្លៃដោយពិន្ទុវាយតម្លៃតាមរាងផលបត្រ សិស្សត្រូវបានផ្តល់ពិន្ទុឱ្យ ដូចតទៅ៖ (៤) ល្អឥតខ្ចោះ (៣) ល្អណាស់ (២) ល្អ និង (១) ត្រូវការការពិចារណាលើការបញ្ចប់ការងាររបស់សិស្សលើសមាសធាតុចំនួនប្រាំមួយនៃ កំណត់ត្រាអំណានដែលសិស្សបានធ្វើលើអត្ថបទទាំងអស់ដែលពួកគេអាន។ ផលបត្រវាយតម្លៃនេះ សម្រួលយកមកពីលោក(Lyutaya, 2011)។

តាមរយៈការស្រាវជ្រាវខាងលើបានបង្ហាញថាសកម្មភាពអាន គឺជាសកម្មភាពស្មុគស្មាញដែលទាក់ទាញអ្នកអាន និងសម្ភារៈសម្រាប់អាន។ សម្ភារៈសម្រាប់អាន អាចរៀបចំតាមវិធីជាច្រើន ដើម្បីអន្ទងចិត្តអ្នកអាន ដោយហេតុថា ការបណ្តុះម្លាប់អាន មានសារសំខាន់ ក្នុងការស្ថាបនាការយល់ដឹង។ ម្យ៉ាងទៀត ការអានឯករាជ្យ តម្រូវឱ្យសិស្សអានអត្ថបទឱ្យបានច្រើនតាមតែអាចធ្វើបាន។ គោលបំណងដើម្បីទទួលបានការយល់ដឹងទូទៅ ឈានទៅរកការយល់ដឹងស៊ីជម្រៅ។ ការអានសេរី អនុញ្ញាតឱ្យសិស្សស្វែងរកភាពរីករាយក្នុងការអាន។ នៅពេលដែលពួកគេទទួលបានការយល់ដឹងទូទៅ អំពីគំនិតនៅក្នុងអត្ថបទ រៀនយុទ្ធសាស្ត្រអាន និងបង្កើត ការលើកទឹកចិត្តរបស់ពួកគេឱ្យមានការយល់ដឹងអំពីឥន្ទ:ក្នុងការអាន(Lyutaya, 2011)ព្រមទាំងលើកទឹកចិត្តសិស្ស ឱ្យកែលម្អបំណិនផ្សេងទៀត (Salameh, 2017)

២.៤ ការវិភាគទិន្នន័យ

បន្ទាប់ពីធ្វើការប្រមូលទិន្នន័យបានមកពីសំណាកទាំងអស់រួចហើយ អ្នកស្រាវជ្រាវបានស្រង់ទិន្នន័យទាំងនោះដាក់តាមលក្ខខណ្ឌនីមួយៗ មុនពេល និងក្រោយពេលប្រើប្រាស់កំណត់ត្រាអំណានលើការអានយល់ន័យ រួចមកធ្វើការប្រៀបធៀបនិងវិភាគទិន្នន័យនោះតាមផ្នែកនៃខ្លឹមសាររបស់ទិន្នន័យ។ ស្ថិតិវិភាគទំនាក់ទំនង [Analysis of covariance(ANCOVA)] ត្រូវបានប្រើ ដើម្បីប្រៀបធៀបភាពប្រែប្រួលលទ្ធផលសិក្សាតាមរយៈតេស្តបញ្ចប់ ហើយតេស្តបញ្ចប់នេះជាអថេរទំនាក់ទំនង (Covariate variables)នៅក្នុងការវិភាគនេះ។ Partial eta squared ត្រូវយកមកក្រើដើម្បីវាស់កម្រិតប្រសិទ្ធភាព(effect size)។ តាមការណែនាំរបស់Cohen (1988) លោកបានលើកឡើងថា តម្លៃ Partial eta squared =0.01 ឡើងទៅ គឺប្រសិទ្ធភាពកម្រិតតិចតួច, ចាប់ពី 0.06 ឡើងទៅ គឺប្រសិទ្ធភាពកម្រិតមធ្យម, ចាប់ពី 0.14 ឡើងទៅ គឺប្រសិទ្ធភាពកម្រិតខ្ពស់។ មុនពេលការពិសោធ តម្លៃស្ថិតិខុសគ្នាដែលបានរកឃើញរវាងក្រុមពិសោធន៍ (Experimental Group) និងក្រុមប្រៀបធៀប(Control Group)ទៅលើលទ្ធផលនៃការអានយល់ន័ ‘យរបស់សិស្ស *(t=1.10, p <0.05* ។

២.៥ ក្រមសីលធម៌នៃការស្រាវជ្រាវ

ការប្រមូលទិន្នន័យសម្រាប់ការស្រាវជ្រាវនេះ អ្នកស្រាវជ្រាវយល់ច្បាស់ពីក្រមសីលធម៌ស្តីពីការស្រាវជ្រាវមានលិខិតបាត់តាំងពីវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ ដូចជាលិខិតឧទ្ទេសនាមដើម្បីបុះ

ធ្វើកម្មសិក្សាគរុកោសល្យរាជធានីភ្នំពេញ ដើម្បីស្នើសុំបុះស្រាវជ្រាវ។ ការស្រាវជ្រាវនេះបានការអនុញ្ញាតពីគណៈគ្រប់គ្រងពីវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញដើម្បីស្នើសុំបុះស្រាវជ្រាវគ្រប់គ្រងសាលាបឋមសិក្សាសន្ធម៉ុកដើម្បីស្នើសុំធ្វើការស្រាវជ្រាវ។ ដើម្បីបានជាទិន្នន័យអ្នកស្រាវជ្រាវ ក៏បានសុំការអនុញ្ញាតគ្រូបន្ទុកថ្នាក់ក្នុងការស្រាវជ្រាវផងដែរ។

ដើម្បីឱ្យអ្នកចូលរួមផ្តល់ពត៌មានច្បាស់និងពិតប្រាកដ អ្នកស្រាវជ្រាវបានបង្ហាញពីគោលបំណងពីការស្រាវជ្រាវ ជូនគ្រូ និងសិស្ស ហើយបង្ហាញពីផលប្រយោជន៍នៃការស្រាវជ្រាវនេះគឺដើម្បីជួយពួកគាត់ធ្វើសកម្មភាពយ៉ាងសកម្ម។ នៅពេលទទួលបានទិន្នន័យពីអ្នកចូលរួមទាំងអស់រួចរាល់ហើយ យើងអ្នកស្រាវជ្រាវត្រូវយកទិន្នន័យទាំងនោះមកប្រើប្រាស់ដោយផ្តល់របាយការណ៍ពេញលេញ និង មានសុច្ចរិតភាពលើឯកទេស មានភាពស្មោះត្រង់និងឯករាជ្យ។


៣. លទ្ធផលស្រាវជ្រាវ

១. វឌ្ឍនភាពនៃការប្រើវិធីបែបកំណត់ត្រាអំណាន លើការអានយល់ន័យរបស់សិស្សថ្នាក់ទី៦ តាមរយៈសន្លឹកកិច្ចការ


តារាងទី១៖ លទ្ធផលនៃការត្រួតពិនិត្យ ការអនុវត្តកំណត់ត្រាអំណានរបស់សិស្សក្រុមពិសោធន៍

ភាគរយសិស្សដែលអនុវត្តបាន	លើកទី១		លើកទី២		លើកទី៣		លើកទី៤		លើកទី៥	
(១)ត្រូវការកែលម្អជ្រើន	32	91.43%	23	65.71%	15	42.86%	8	22.86%	03	8.57%
(២) ត្រូវការកែលម្អតិចតួច	03	8.57%	09	25.71%	13	37.14%	14	40.00%	05	14.29%
(៣) ល្អ	00	0%	03	8.57%	06	17.14%	10	28.57%	16	45.71%
(៤) ល្អណាស់	00	0%	00	0%	01	2.86%	3	8.87%	11	31.43%

ក្រាហ្វសសរបង្ហាញពីការកើនឡើងនៃភាពត្រឹមត្រូវនៃការបំពេញកំណត់ត្រាអំណានរបស់សិស្សក្រុមពិសោធន៍



តារាងទី២ ៖ ក្រាហ្វខ្សែបង្ហាញពីការថយចុះនៃការកែលម្អ និងកើនឡើងនៃការអានយល់ន័យ



តារាងទី១ខាងលើបង្ហាញថា សម្រាប់ការអនុវត្តកំណត់ត្រាអំណានលើកទី១ សិស្សចំនួន ៩១.៤៣% ត្រូវការការកែលម្អប្រើន, សិស្សចំនួន៨.៥៧% ត្រូវការកែលម្អតិចតួច ឯសិស្សដែលអាចធ្វើបានល្អនិងល្អណាស់ ពុំមានទេ។ សម្រាប់ការអនុវត្តកំណត់ត្រាអំណានលើកទី២ សិស្សចំនួន ៦៥.៧១% ត្រូវការការកែលម្អប្រើន, សិស្សចំនួន២៥.៧១% ត្រូវការកែលម្អតិចតួច, សិស្សចំនួន ៨.៥៧%ធ្វើបានល្អ ហើយពុំមានសិស្សដែលធ្វើបានល្អណាស់ទេ។ សម្រាប់ការអនុវត្តកំណត់ត្រាអំណានលើកទី៣ សិស្សចំនួន៤២.៨៦% ត្រូវការការកែលម្អប្រើន, សិស្សចំនួន៣៧.១៤% ត្រូវការកែលម្អតិចតួច, សិស្សចំនួន១៧.១៤%ធ្វើបានល្អ ហើយសិស្សដែលធ្វើបានល្អណាស់មានចំនួន២.៨៦%។ សម្រាប់ការអនុវត្តកំណត់ត្រាអំណានលើកទី៤ សិស្សចំនួន២២.៨៦% ត្រូវការការកែលម្អប្រើន, សិស្សចំនួន៤០% ត្រូវការកែលម្អតិចតួច, សិស្សចំនួន២៨.៥៧%ធ្វើបានល្អ ហើយសិស្សដែលធ្វើបានល្អណាស់មានចំនួន៨.៨៧%។ សម្រាប់ការអនុវត្តកំណត់ត្រាអំណានលើកទី៥ សិស្សចំនួន៨.៥៧% ត្រូវការការកែលម្អប្រើន, សិស្សចំនួន១៤.២៩% ត្រូវការកែលម្អតិចតួច, សិស្សចំនួន៤៥.៧១%ធ្វើបានល្អ ហើយសិស្សចំនួន៣១.៤៣%ធ្វើបានល្អណាស់។

តារាងទី១ខាងលើនេះក៏បង្ហាញផងដែរថា តាមរយៈការត្រួតពិនិត្យទាំងប្រាំលើក សិស្សដែលត្រូវការកលម្អប្រើនបានថយចុះពី៩១.៤៣%នៅលើកទី១ មក ៨.៥៧%នៅលើកទី៥។ សិស្សដែលត្រូវការកែលម្អតិចតួច បានកើនឡើងពី៨.៥៧%នៅលើកទី១ ទៅ១៤.២៩%នៅលើកទី៥។ សិស្សដែលអនុវត្តបានល្អបានកើនឡើងពី០០%នៅលើកទី១ ទៅ៤៥.៧១%នៅលើកទី៥។ សិស្សដែលអនុវត្តបានល្អណាស់បានកើនឡើង០០%នៅលើកទី១និងទី២ ទៅ៣១.៤៣%នៅលើកទី៥។ នេះមានន័យថា ការកត់ត្រារបស់សិស្សមានការកើនឡើង។ តាមរយៈការអនុវត្តកំណត់ត្រាអំណាន សិស្សមានការអានយល់ន័យប្រើនជាងមុន តាមរយៈការត្រួតពិនិត្យនិងផ្តល់ព័ត៌មានត្រឡប់ជាប្រចាំរបស់គ្រូបង្រៀនដល់សិស្ស។

២. លទ្ធផលសិក្សា មុននិងក្រោយពេលប្រើវិធីបែបកំណត់ត្រាអំណាន ដើម្បីជំរុញការអានយល់ន័យរបស់សិស្សថ្នាក់ទី៦មុខវិជ្ជាភាសាខ្មែរ

តម្លៃមធ្យមនិងគម្លាត សម្រាប់បុរេតេស្ត និង តេស្តបញ្ចប់នៃការបង្រៀន សម្រាប់ក្រុមពិសោធន៍

និងក្រុមធម្មតា ដែលបានបង្ហាញក្នុងតារាងទី៣។ លទ្ធផលនៃការវិភាគសម្រាប់បង្ហាញពីភាពខុសគ្នានៃវិធីកំណត់ត្រាអំណាន ដើម្បីជំរុញការអានយល់**ន័យ**ទៅលើសិស្សថ្នាក់ទី៦ បានបង្ហាញក្នុងតារាងទី៤។

តារាងទី៤៖ តម្លៃមធ្យម និងគម្លាតស្តង់ដា សម្រាប់ពិន្ទុបុរេតេស្ត និង តេស្តបញ្ចប់នៃសិស្សថ្នាក់ទី៦

Group	N	Pre-test		Post-test	
		M	SD	M	SD
Experimental	39	6.46	1.94	7.12	1.75
Control	32	5.75	2.04	5.53	1.93

តារាងទី៥ លទ្ធផលANCOVAនៃប្រសិទ្ធភាពនៃវិធីកំណត់ត្រាអំណាន ដើម្បីជំរុញការអានយល់ន័យ ទៅលើសិស្សថ្នាក់ទី៦

Dependent Variable: post-test

Source	df	Mean Square	F	Sig.	Partial ^{2}
Corrected Model	2	48.08	18.05	.00	.34
Intercept	1	89.52	33.62	.00	.33
pretest	1	51.97	19.52	.00	.22
Group	1	27.73	10.41	.002	.13
Error	68	2.66			

Note: P <.05; R Squared = .347 (Adjusted R Squared = .328)

លទ្ធផលក្នុងតារាងខាងលើបង្ហាញថា មានភាពខុសគ្នារវាងពិន្ទុតេស្តក្រោយពេលពិសោធន៍របស់សិស្សទាំងពីរក្រុម, F (1, 68) = 27.73, P <0.05។ ចំណេះដឹងមុនពេលពិសោធន៍ក៏មានឥទ្ធិពលទៅលើចំណេះដឹងក្រោយពេលពិសោធន៍ដែរ, F (1,68) = 19.52, P<0.05។ លទ្ធផលស្រាវជ្រាវបង្ហាញថា សិស្សដែលរៀនតាមយុទ្ធវិធីអានយល់ន័យបានល្អជាងសិស្សដែលរៀនតាមបែបប្រពៃណី។

៣. ប្រសិទ្ធភាពនៃការប្រើវិធីបែបកំណត់ត្រាអំណាន ដើម្បីជំរុញការអានយល់ន័យរបស់សិស្សថ្នាក់ទី៦

លទ្ធផលក្នុងតារាងទី២ខាងលើបង្ហាញថា វាមានភាពខុសគ្នារវាងពិន្ទុតេស្តក្រោយពេលពិសោធន៍របស់សិស្សទាំងពីរក្រុម, F (1, 68) = 27.73, P <0.05, Partial ^{2}=0.13 ប៉ុន្តែកម្រិតឥទ្ធិពលគឺខ្លាំង។ ចំណេះដឹងមុនពេលពិសោធន៍ក៏មានឥទ្ធិពលទៅលើចំណេះដឹងក្រោយពេលពិសោធន៍ដែរ, F (1,68) = 19.52, Partial ^{2} = 0.22 តែក្នុងករណីនេះ កម្រិតឥទ្ធិពលគឺខ្លាំងផងដែរ។ លទ្ធផលស្រាវជ្រាវបង្ហាញថា សិស្សដែលរៀនដោយប្រើវិធីកំណត់ត្រាអំណាន ទទួលបានប្រសិទ្ធភាពក្នុងការអានយល់ន័យបានល្អជាងសិស្សដែលរៀនតាមបែបប្រពៃណី ព្រោះតម្លៃនៃការវិភាគស្ថិតនៅក្នុងកម្រិតខ្លាំង។

៤. លទ្ធផលនៃការសិក្សារបស់សិស្សប្រុស និងសិស្សស្រីចំពោះការប្រើវិធីកំណត់ត្រាអំណាន

តារាងទី៦៖ ស្ថិតិពណ៌នា អំពីតម្លៃមធ្យម គម្លាតស្តង់ដា នៃលទ្ធផលសិក្សារវាងសិស្សប្រុស និងសិស្សស្រីថ្នាក់ទី៦

gender	N	Mean	Std. Deviation	*t-value*
Male	34	6.10	2.12	.36
Female	37	6.70	1.84	.30

តារាងទី៧៖ បង្ហាញពីលទ្ធផលនៃ Independent Samples Test លើការសិក្សារវាងសិស្សប្រុស និងសិស្សស្រី ថ្នាក់ទី៦

Levene's Test		t-test for Equality of Means						
F	Sig.	t	df	Sig. (2-tailed)	Mean Dif.	Std. ED	95% CID	
							Lower	Upper
.49	.48	-1.28	69	.204	-.60	.47	-1.54	.33
		-1.27	65.67	.207	-.60	.47	-1.54	.34

តារាងទី៧ បង្ហាញថា វាមានភាពដូចគ្នារវាងកម្រិតនៃការរៀនតាមបែបកំណត់ត្រាអំណានរបស់សិស្សស្រី និងសិស្សប្រុស, $t=(69)=-1.28$, $p>0.05$។ លទ្ធផលនេះបង្ហាញថា សិស្សប្រុស និងសិស្សស្រី រៀនបានលទ្ធផលដូចគ្នា។ ដូច្នេះសិស្សប្រុសនិងសិស្សស្រីរៀនដោយប្រើវិធីបែបកំណត់ត្រាអំណាននេះបានដូចគ្នា មិនរើសអើងភេទឡើយ។

៥.ទស្សនៈយល់ឃើញអំពីការប្រើវិធីកំណត់ត្រាអំណានក្នុងការជំរុញការអានយល់ន័យរបស់សិស្ស

ភាពពេញចិត្តក្នុងការប្រើវិធីកំណត់ត្រាអំណាន

ការប្រើវិធីកំណត់ត្រាអំណាន ធ្វើឱ្យសិស្សមានការរីកចម្រើនលទ្ធផលនៃការសិក្សា ទាំងទស្សនៈយល់ឃើញជាវិជ្ជមានចំពោះការប្រើវិធីនេះផងដែរ។ តាមរយៈការវិភាគលទ្ធផលនៃការសិក្សាខាងលើបង្ហាញពីការរីកចម្រើនគួរឱ្យកត់សម្គាល់។ មិនតែប៉ុណ្ណោះ សិស្សក៏មានភាពពេញចិត្តក្នុងការទទួលយកវិធីកំណត់ត្រាអំណាននេះផងដែរ ដោយហេតុថា ការប្រើវិធីនេះរយៈពេលតែដប់សប្តាហ៍ ធ្វើឱ្យសិស្សមានភាពងាយស្រួលក្នុងការរៀនមុខវិជ្ជាភាសាខ្មែរ ក៏ដូចជាមុខវិជ្ជាដទៃទៀត។ ជាក់ស្តែងតាមរយៈការប្រមូលទិន្នន័យពីការសម្ភាសន៍បានបង្ហាញថា សិស្សមិនបានជួបការលំបាកក្នុងពេលរៀនមុខវិជ្ជាភាសាខ្មែរទេ មិនតែប៉ុណ្ណោះ សិស្សមួយ90%បានបង្ហាញពីការចូលចិត្តមុខវិជ្ជាភាសាខ្មែរទៀតផង។ ដោយហេតុថា មុខវិជ្ជាភាសាខ្មែរបានដើរតួរនាទីយ៉ាងសំខាន់ក្នុងការបំពេញបន្ថែមនូវជំនាញទាំង៤ ដែលមាន

ការអាន ស្តាប់ និយាយ និងសរសេរ។ តួយ៉ាងសិស្ស១០០%បានបង្ហាញអាកប្បកិរិយាវិជ្ជមានទៅលើការរៀនមុខវិជ្ជាភាសាខ្មែរ ដោយពួកគេមិនបានលើកឡើងការលំបាកឬឧបសគ្គនោះទេ។ ពួកគេបន្ថែមទៀតថាភាសាខ្មែរជាមុខវិជ្ជាងាយរៀន ដែលមានសិស្សចូលចិត្តច្រើន។ បន្ថែមលើនេះទៀត សិស្ស៨0%បានបង្ហាញពីចំណាប់អារម្មណ៍លើផ្នែកដំនាញសរសេរ ពោលគឺសរសេតាមអាន។ ជាក់ស្តែងសិស្ស*S3* បានលើកឡើងថា *"ជាធម្មតាខ្ញុំចូលចិត្តភាសាខ្មែរដែរ ប៉ុន្តែខ្ញុំចូលចិត្តបែបសរសេរតាមអាន។"* ជាមួយគ្នានេះដែរ សិស្ស *S1* បានបង្ហាញចំណាប់អារម្មណ៍ថា *"ខ្ញុំគិតថាខ្លួនខ្ញុំចេះជាងមុន [...] លើការអាន ការឆ្លើយសំណួរ ការសរសេរលើកិច្ចការដែលអ្នកគ្រូដាក់ឱ្យ។"* ទាំងនេះ បង្ហាញពីភាពពេញចិត្តរបស់សិស្សលើការរៀនបែបកំណត់ត្រាអំណាន។

ការអាន និងសារប្រយោជន៍នៃការអាន

ការយល់ដឹងពីសារសំខាន់នៃការអាន ក្រោយប្រើវិធីសាស្ត្រកំណត់ត្រាអំណាន ជាសញ្ញាណមួយដ៏ល្អក្នុងការអនុវត្តវិធីសាស្ត្រនេះ។ តាមរយៈ ទិន្នន័យពីការសម្ភាសន៍សិស្សថ្នាក់ទី៦បានបង្ហាញថាសិស្សមានចំណង់ចំណូលចិត្តផ្សេងៗពីគ្នាទៅលើប្រភេទនៃអំណាន ហើយការអានបានដើរតួរនាទីយ៉ាងសំខាន់សម្រាប់អភិវឌ្ឍការអានស្ទាត់ ការយកចិត្តទុកដាក់លើការស្វែងយល់អត្ថបទជាងមុន និង ប្រាជ្ញាស្មារតីដល់សិស្ស។ នៅក្នុងការអាន ប្រភេទអត្ថបទអំណានបែប រឿងព្រេងកថា ផ្សងព្រេង ព្រេងនិទាន មានសិស្សនិយមអានជាងគេ ចំណែករឿងប្រភេទប្រជាប្រិយ ប្រឌិត ឬអត្ថបទបែបវិទ្យាសាស្ត្រក៏មានការគាំទ្រពីកុមារគួរឱ្យគាត់សម្គាល់ផងដែរ។ ជាក់ស្តែងសិស្ស*S5 បានលើកឡើងថា "ខ្ញុំចូលចិត្តអានដែរ [...] ហើយចូលចិត្តបែបរឿងផ្សងព្រេង រឿងនិទាន រឿងវេទមន្តអី។"* បើទោះបីជាសិស្សមានមានចម្រុះភាពនៃប្រភេទអត្ថបទអំណានក្តី ក៏ពួកគេនៅតែចង្អុលបង្ហាញទៅរកចំណុចស្រដៀងគ្នាមួយចំនួនធំទៅលើការផ្តល់អត្ថប្រយោជន៍នៃការអានផងដែរ។ សិស្ស៧0%បានលើកឡើងថា ការអានជួយឱ្យពួកគេមានភាពវៃឆ្លាតជាងមុន បង្កើនការចងចាំ ពង្រីកចំណេះដឹងដែលមានស្រាប់ឱ្យកាន់តែទូលំទូលាយ ផ្តល់តម្លៃអប់រំនិងគំនិតល្អៗ។ បន្ថែមពីនេះ ក៏មានការអភិវឌ្ឍការអានយល់ន័យផងដែរ ដូចជាការរៀនពាក្យថ្មីៗ យល់ពីអត្ថន័យនៃពាក្យ ចងចាំពាក្យបានល្អជាដើម។ ជាក់ស្តែងសិស្ស*S6*បង្ហាញចំណាប់អារម្មណ៍ថា *"ពេលខ្លះយល់ពីអំណានហើយយល់ពីតម្លៃអប់រំនៃរឿង យល់អត្ថន័យពាក្យពាក្យពិបាកបន្សល់ពាក្យ ធ្វើឱ្យខ្ញុំចងចាំបានយូរ។ ...វាបានអប់រំយើងឧទាហរណ៍រឿងអ្នកតាឃ្លាំងមឿងអី ហើយអាចដឹងប្រវត្តិរបស់អ្នកតាឃ្លាំមឿង[...]។"* ដោយឡែក ពួកគេមិនសូវទទួលបានឱកាសអានអត្ថបទដោយឡែកពីសៀវភៅសិក្សាគោលច្រើននោះទេ ពីមុនមក។ ការនាំឱ្យសិស្សអានដោយសេរីលើអត្ថបទផ្សេងៗធ្វើឱ្យសិស្សចង់អាន ដែលនាំទៅដល់ការយល់ដឹងពីសារសំខាន់នៃការអាន។

ការរៀបចំដំហាននៃកំណត់ត្រាអំណាន និងភាពខ្លាំងរបស់វា

តាមរយៈការអនុវត្តដំហាននៃកំណត់ត្រាអំណាន សិស្សបានរំឭកឡើងវិញនូវវិធីដែលពួកគបានធ្វើ រួមមានការជ្រើសរើសអំណាន ឬអត្ថបទ ការអានអត្ថបទឬអំណានដែលបានជ្រើសរើស ការសង្ខេបឬឆ្លុះបញ្ចាំងរួចកត់ត្រា និងការធ្វើការបង្ហាញ។ ឥទ្ធិពលនៃការអនុវត្តតាមដំហាននៃកំណត់ត្រាអំណាន

បន្ទាប់ពីសិស្សបានអនុវត្ត ជាសញ្ញាមួយបង្ហាញថា វិធីសាស្ត្រនេះល្អ អាចជួយការអានស្ទាត់ ការអានយល់ន័យ ការបង្កើនព័ត៌មាន និងចំណេះដឹងយល់ពីអត្ថបទហើយ ស្គាល់ន័យពាក្យបង្កើតឱកាស ឱ្យសិស្សបានស្វែងយល់ដឹងពីអត្ថបទថ្មីៗនិងប្លែកៗ ព្រមទាំងបង្កើនភាពសប្បាយរីករាយជាមួយគ្នានេះផងដែរ។ ដូចអ្វីដែលបានលកឡើងខាងលើ សិស្ស S6 យល់ថា *"ការធ្វើតាមអ្នកគ្រូដាក់កិច្ចឱ្យធ្វើ អ្នកគ្រូប្រាប់ពីការសរសេរខុស ខ្ញុំបានកែនៅពេលសរសេរចម្លើយលើកិច្ចការលើកក្រោយ បានអត់ស្រវឹខុស[...]។ ខ្ញុំគិតថាអ្វីដែលអ្នកគ្រូដាក់ឱ្យធ្វើ ជាវិធីល្អដែលធ្វើសិស្សខំរៀន[...]។"* នៅពេលសិស្សធ្វើតាមការណែនាំ និងអ្វីដែលគ្រូបង្រៀនចង់បាន សិស្សអាចមិនទាន់យល់ពីសារសំខាន់និងការអភិវឌ្ឍខ្លួន បន្ទាប់ពីសិស្សធ្វើបានល្អជាងមុនលើ មានភារកិចម្រើនជាងមុន លើការអានយល់ន័យ ការសរសេរឆ្លុះបញ្ចាំង វាជាហេតុធ្វើឱ្យសិស្ស កាន់តែយល់ពីសារសំខាន់នៃការអាន និងកំណត់បានថា វិធីបែបកំណត់ត្រាអំណានមានសារសំខាន់សម្រាប់ការសិក្សា។

វឌ្ឍនភាពក្រោយអំណាន

កំណត់ត្រាអំណាន ផ្តល់ឱ្យសិស្សនូវការអភិវឌ្ឍជំនាញអាន ពាក្យថ្មី ការរីកចម្រើនផ្នែកចំណេះដឹងផ្សេងៗសម្បូរបែប អានអំណានឆាប់យល់ជាងមុនជាដើម។ ចំពោះការគិតក៏បានប្រសើរជាងមុន ដោយសិស្សបាននិយាយទាំងទឹកមុខរីករាយលើប្រសិទ្ធិភាពនិងការអភិវឌ្ឍដែលពួកគេទទួលបានពីកំណត់ត្រាអំណានផងដែរ។ តាមរយៈការសម្ភាស សិស្សបានផ្តល់ព័ត៌មានជាច្រើនពីវឌ្ឍនភាពបន្ទាប់ពីការអនុវត្តវិធីកំណត់ត្រាអំណាន។ ជាក់ស្តែង សិស្សទាំងអស់ បានលើកឡើងស្រដៀងគ្នាពីការរីកចម្រើនក្រោយពេលអានរឿងច្រើននិងធ្វើកិច្ចការជាប្រចាំ។ សិស្ស*S2* ថា *"ខ្ញុំអានបានល្អជាងមុន ដោយមិនបាច់ប្រកប អានហើយ អាចដឹងពីន័យរបស់រឿង អាចឆ្លើយសំណួរ ធ្វើការងារគ្រូបាន។"*

៤. ការពិភាក្សា

ការសិក្សាស្រាវជ្រាវនេះ ពិនិត្យមើលប្រសិទ្ធភាពនៃវិធីកំណត់ត្រាអំណាន លើការអានយល់ន័យរបស់សិស្សថ្នាក់ទី៦។ លទ្ធផលវិភាគតាមANCOVA បង្ហាញថាការអានយល់ន័យមានការរីកចម្រើនលើក្រុមពិសោធ ដោយផ្អែកលើស្ថិតិ។ នេះមានន័យថា ការប្រើកំណត់ត្រាអំណានមានប្រសិទ្ធភាពក្នុងការបង្កើនការអានយល់ន័យរបស់សិស្សថ្នាក់ទី៦។ នេះក៏ដោយសារ នៅក្នុងដំណើរការកំណត់ត្រាអំណាន សិស្សជាប់ពាក់ព័ន្ធនឹងកិច្ចការនៃការអាន បានរំលឹកឡើងវិញនូវវិធីដែលពួកគបានធ្វើរួមមាន (ការជ្រើសរើសអំណានឬអត្ថបទ, អានអត្ថបទឬអំណានដែលបានជ្រើសរើស, សង្ខេបឬឆ្លុះបញ្ចាំងរួចកត់ត្រា និង ការធ្វើការបង្ហាញ)។ ចំពោះលោកAulia (2019) លោកបានលើកឡើងផងដែរថា ឥទ្ធិពលរបស់កំណត់ត្រាអំណានបន្ទាប់ពីសិស្សបានអនុវត្ត សិស្សអាចបង្កើនសមត្ថភាពលើការអានយល់ន័យ បង្កើនព័ត៌មាន និងចំណេះដឹងយល់ដឹងពីអត្ថបទ ហើយ ស្គាល់ន័យនៃពាក្យ។ ជាមួយគ្នានេះផងដែរLyutaya (2011) វឌ្ឍនភាពទាំងនេះ បង្កើតឱកាសឱ្យសិស្សបានស្វែងយល់ពីអត្ថបទថ្មីៗ និងប្លែកៗ ហើយបង្កើនភាពសប្បាយរីករាយ។ ការរកឃើញទាំងនេះ ក៏បានជួយគាំទ្រដល់ការរកឃើញមុនៗផងដែរដែលបានបង្ហាញថាសិស្សអាចអភិវឌ្ឍការអានយល់ន័យបាន ចំពោះថ្នាក់ដែលប្រើវិធីបង្រៀនបែប

កំណត់ត្រាអំណាន((Currier, 2013; Decarbo, 2023) ។

ការសិក្សានេះក៏បានរកឃើញផងដែរថា សិស្សមានទស្សនៈយល់ឃើញជាវិជ្ជមាន ទៅលើការប្រើប្រាស់កំណត់ត្រាអំណាន ដោយសិស្សភាគច្រើនមិនមានបញ្ហានឹងការរៀនភាសាខ្មែរនោះទេ ក្រោយអនុវត្តវិធីនេះ។ លើសពីនេះ សិស្សក៏ចូលចិត្តការអានអំណានក្រៅពីសៀវភៅសិក្សាគោល ដែលភាគច្រើនជាប្រភេទអត្ថបទបែបផ្សងព្រេង រឿងប្រឌិត និងរឿងព្រេងនិទាន។ តែគួរឱ្យស្តាយពួកគេមិនសូវមានឱកាសបានអានច្រើននោះទេ។ ពួកគេបានបង្ហាញទឹកមុខរីករាយ ដោយបានលើកឡើងពីគុណប្រយោជន៍ជាច្រើននៃកំណត់ត្រាអំណាន។ ការសិក្សានេះបានបង្ហាញលទ្ធផលស្រដៀងគ្នានឹង ការស្រាវជ្រាវរបស់(Rakana, 2017) និង(Lyutaya, 2011; Ro, 2016) ផងដែរ។ ដោយការស្រាវជ្រាវនោះទាំងនោះបានបង្ហាញថា សិស្សភាគច្រើនចាប់ពី 70.45% ទៅ 90.91% បានយល់ស្របនឹងរាល់ការអះអាងដែលបង្ហាញថាសិស្សមានអាកប្បកិរិយាវិជ្ជមានចំពោះការប្រើប្រាស់កំណត់ហេតុនៃការអាន។ ភាគរយខ្ពស់បំផុតនៃសិស្ស(90.91%) បានយល់ស្របនឹងការអានតាមបែបកំណត់ត្រាអំណានអនុញ្ញាតឱ្យពួកគេជ្រើសរើសព័ត៌មាននៅក្នុងរឿង មកអានបានដោយសេរី។ សិស្សភាគច្រើនបានពន្យល់ថា កំណត់ហេតុនៃការអានធ្វើឱ្យសិស្សយល់រឿងរ៉ាវកាន់តែច្រើន។ ការក្រឡេកមើលឱ្យកាន់តែជិតដល់លើការសរសេររបស់សិស្សអំពីសេចក្តីសង្ខេបរឿងនៅក្នុងកំណត់ហេតុការអានរបស់ពួកគេ បានរកឃើញថា ពួកគេមួយចំនួនបានយល់ខុសអំពីរឿងនៅក្នុងកំណត់ហេតុដំបូងរបស់ពួកគេ។ ទោះជាយ៉ាងណាក៏ដោយ នៅពេលដែលពួកគេបានសង្ខេបរឿងទាំងមូលនៅក្នុងកំណត់ត្រាអំណានចាប់ទីបួនទៅរបស់ពួកគេ ពួកគេហាក់ដូចជាយល់យ៉ាងច្បាស់ មានភាគរយកើនឡើង។ ដូច្នេះ កំណត់ហេតុអានរបស់សិស្ស ផ្តល់ការគាំទ្រសម្រាប់ហេតុផលដែលពួកគេបានផ្តល់(Rakana, 2017) ។

៥. សេចក្តីសន្និដ្ឋាន និង អនុសាសន៍

ការសិក្សានេះ ពិនិត្យប្រសិទ្ធភាពនៃវិធីកំណត់ត្រាអំណានលើលទ្ធផលសិក្សារបស់សិស្សថ្នាក់ទី ៦ ។ តាមរយៈការអនុវត្តផ្ទាល់នៃវិធីកំណត់ត្រាអំណាន និងការប្រមូលទិន្នន័យបន្ទាប់ពីអនុវត្តវិធីសាស្ត្រនេះ ដោយការជ្រើសរើសថ្នាក់ទី៦ចំនួនពីរថ្នាក់គឺថ្នាក់ទី៦មួយថ្នាក់ជា ក្រុមពិសោធ និងថ្នាក់ទី៦មួយថ្នាក់ទៀត ជាក្រុមប្រៀបធៀប។ តាមរយៈការពិសោធនេះ យើងទទួលបានលទ្ធផលវិជ្ជមានគួរជាទីកត់សម្គាល់ ពោលគឺការប្រើវិធីកំណត់ត្រាអំណានមានប្រសិទ្ធភាពលើការអានយល់ន័យរបស់សិស្សកាន់តែប្រសើរ ជាពិសេសចាប់ពីកំណត់ត្រាទីបួនទៅ។

វិធីកំណត់ត្រាអំណានបានពង្រឹងដល់ការអានយល់ន័យដល់សិស្ស។ តាមរយៈតេស្តមុននិងក្រោយពេលអនុវត្តវិធីសាស្ត្របានបង្ហាញពីគម្លាតលទ្ធផលវិជ្ជមានបញ្ជាក់ពីភាពខុសគ្នានៅមុន និងក្រោយពេលប្រើវិធីសាស្ត្រកំត់ត្រាអំណាន។ ស្របជាមួយគ្នានេះដែរសិស្សក៏មានទស្សនៈយល់ឃើញវិជ្ជមានទៅលើការប្រើប្រាស់វិធីកំណត់ត្រាអំណាន ក្នុងការជំរុញការអានយល់ន័យ។ បន្ថែមពីការអានយល់ន័យ កំណត់ត្រាអំណានបានបង្កើតឱកាសឱ្យសិស្សអាននិងទទួលព័ត៌មានថ្មីៗនិងអនុញ្ញាតឱ្យសិស្សអភិវឌ្ឍបំណិនបន្ថែមជាច្រើន មានដូចជា ការកែចម្រើនការរៀនពាក្យថ្មីៗ យល់ពីអត្ថន័យនៃពាក្យ

ចងចាំពាក្យបានល្អជាដើម។ ជាពិសេសកំណត់ត្រាអំណាន ក៏បានផ្តល់ផលវិជ្ជមានទៅលើផ្នែកបញ្ញាស្មារតីដោយសិស្សមានភាពឆ្លាតវៃជាងមុនប្រកបដោយភាពពេញចិត្ត មានឆន្ទៈក្នុងការបន្តការសិក្សាឆ្លងកូមិសិក្សាដោយភាពជឿជាក់។

អនុសាសន៍

តាមរយៈលទ្ធផលនៃការស្រាវជ្រាវលើប្រធានបទវិធីកំណត់ត្រាអំណាន ដើម្បីពង្រឹងការអានយល់ន័យរបស់សិស្សនៅបឋមសិក្សាថ្នាក់ទី៦ ឃើញថាវិធីសាស្ត្រនេះបានផ្តល់គុណប្រយោជន៍យ៉ាងធំធេង យើងឃើញថាសមត្ថភាពអានរបស់សិស្សមានការកើនឡើងគួរឱ្យកត់សម្គាល់ និងទទួលបានលទ្ធផលល្អប្រសើរជាប្រើន ហើយថែមទាំងសម្រេចបានគូរវត្ថុបំណងរបស់គ្រូក្នុងការអនុវត្តវិធីសាស្ត្រ ក៏ដូចជាវត្ថុបំណងនៃការសិក្សាស្រាវនេះផងដែរ។ ទោះជាយ៉ាងណាក៏ដោយការស្រាវជ្រាវនេះដូចគ្នានឹងនឹងការសិក្សាស្រាវជ្រាវមុនៗដែរ។ ការសិក្សានេះមានដែនកំណត់ដែលមានទំហំស្រាវជ្រាវ ធ្វើការពិសោធតែមួយថ្នាក់ ដូច្នេះហើយការស្រាវជ្រាវនេះក៏មិនបានធំទូលាយដែរ ដែលការសិក្សាបន្ត ដោយអនុវត្តវិធីសាស្ត្រនេះ គួរបន្ថែមវិសាលភាពកាន់តែធំទូលាយទៅលើកម្រិតថ្នាក់ផ្សេងទៀត មុនវិជ្ជាផ្សេងទៀតហើយ អនុវត្តកាន់តែប្រើននិងប្រើរយៈពេលយូរជាងនេះ ដើម្បីឱ្យសិស្សមានឱកាសគ្រប់គ្រាន់ពេលអាននិងសំយោគផងដែរ និងទទួលបានភាពជាក់លាក់។ ចំពោះគ្រូបង្រៀនគ្រូត្រូវយកចិត្តទុកដាក់ទៅលើការបែងចែកក្រុមក្នុងការអានអត្ថបទនិងចែករំលែកក្នុងក្រុម ក៏ដូចជាក្នុងថ្នាក់ទាំងមូល ព្រមទាំងលើកទឹកចិត្តឱ្យសិស្សសហការគ្នា ពាក់ព័ន្ធជាមួយគ្នាក្នុងការរៀន បង្រៀនគ្នា និងផ្តល់ព័ត៌មានត្រឡប់ឱ្យគ្នាទៅវិញទៅមក ព្រមទាំងការចែករំលែកប្រភពឯកសារផ្សេងៗឱ្យគ្នាក្នុងថ្នាក់។ ជាមគ្នានេះផងដែរ គ្រូបង្រៀនក៏ត្រូវ ត្រួតពិនិត្យការរីកចម្រើន និងសម្របសម្រួលការសិក្សារបស់សិស្សជាប្រចាំផងដែរ។ គ្រូក៏ត្រូវផ្តល់ជាប្រចាំផងដែរ គឺ ការអនុវត្តកំណត់ត្រាអំណានធ្វើបែបនេះគឺអាចឱ្យសិស្សមានឱកាសក្នុងការបង្ហាញនូវភាពរីកចម្រើនរបស់ពួកគេ ហើយថែមទាំងជួយគាំទ្រអំណានឱ្យ លើកពីនេះគ្រូបង្រៀនក៏ត្រូវតែសិក្សាស្វែងយល់បន្ថែមទៀតនូវបំណុចដែរធ្វើមិនទាន់បានប្រសើរលើការអភិវឌ្ឍការអានយល់ន័យជួយលើកកម្ពស់សមត្ថភាពអានរបស់សិស្សឱ្យបានកាន់តែប្រើនទៀត ដើម្បីឱ្យការបង្រៀនកាន់តែមានប្រសិទ្ធភាព។

ឯកសារយោង

Wu, L., Valcke, M., & Keer, H. V. (2019). Factors associated with reading comprehension of secondary school students. *Educational Sciences: Theory and Practice, 19* (4), 34-47. doi:http://dx.doi.org/10.12738/estp.2019.4.003

Alexander, P. A. (2005). The role of prior knowledge in comprehension. In M. J. Snowling & C. Hulme (Eds.), *The science of reading: A handbook* (pp. 222-239). Malden: MA: Blackwell.

Alfassi, M. (2004). Reading to Learn: Effects of Combined Strategy Instruction on High School Students. *The Journal of Educational Research, 97*(4), 171-185. doi:10.3200/JOER.97.4.171-185

Aulia, V. (2019). Promoting extensive reading activity by constructing reading log project in
EFL class. *Research and Innovation in Language Learning, 2*(2), 101-119. doi:https://doi.org/10.33603/rill.v2i2.2042

Clements, J. (2023a, 2023). How can reading comprehension best be taught? Retrieved from https://www.oxfordowl.co.uk/welcome-back/for-school-back/pathways-page/pathwayslist/teaching-comprehension/background-questions-tc/wales--16/how-can-reading-comprehension-best-be-taught--2

Clements, J. (2023b). What are the factors associated with good comprehension? Retrieved from https://www.oxfordowl.co.uk/welcome-back/for-school-back/pathways-page/pathwayslist/teaching-comprehension/background-questions-tc/wales--16/what-are-the-factors-associated-with-good-comprehension--2

Cohen, J. (1988). *Statistical power analysis for the behavioral sciences* (2nd ed.). New York: Lawrence Erlbaum Associates.

Currier, E. J.-L. (2013). *Using reading logs to improve comprehension of science text.* (Master of Science in Science Education), Montana State University-Bozeman, Bozeman, Montana. Retrieved from https://scholarworks.montana.edu/xmlui/bitstream/handle/1/2771/CurrierE0813.pdf?sequence=1

Decarbo, C. (2023). Comprehension reading logs for comprehension and nightly reading. Retrieved from https://www.missdecarbo.com/reading-logs/

Diptoadi, V. L. (2019). Students′perception of extensive reading activity through reading log. *Magister Scientiae, 2*(46), 201-215. doi:https://doi.org/10.33508/mgs.v2i46.2227

Dorasamy, R. (2017). *Reading habits of grade 6 pre-adolescents at a primary school in Ottawa, KwaZulu-Natal.* (Master of Education), University of KwaZulu-Natal. KwaZulu-Natal.

Ferlazzo, L. (2023). Response: Reading Logs Should Be Tools for ‘Students to Spy on Themselves’. Retrieved from https://www.edweek.org/teaching-learning/opinion-response-reading-logs-should-be-tools-for-students-to-spy-on-themselves/2019/07

Hang, C. N. (2016). *Education Reform in Camboida: Toward aKnowledge-Based Society and Shard Properity*. Phnom Penh: Sipar Publishing.

Holland, N. N. (1989). *The dynamics of literary response*: Columbia University Press.

Kalman, C. S. (2011). Enhancing Students’ Conceptual Understanding by Engaging Science Text with Reflective Writing as a Hermeneutical Circle. *Science & Education, 20*(2), 159-172. doi:10.1007/s11191-010-9298-z

Kalsum, K., Rauf, F. A., & Sardi, A. (2023). Implementation of Reading-Log to Increase Students’ Interest on Literacy at Islamic Boarding School. *IDEAS: Journal on English Language Teaching and Learning, Linguistics and Literature, 10*(2), 1887-1898. doi:10.24256/ideas.v10i2.3202

Khonamri, F., & Farzanegan, M. (2016). Literature-based extensive reading accompanied by reading logs: A case for developing critical thinking skills of English literature students. *International Journal of Education, 9*(1), 59-68. doi:https://doi.org/10.17509/ije.v9i1.3719

Kintsch, W. (1988). The role of knowledge in discourse comprehension: a construction-integration model. *Psychological review, 95*(2), 163. doi:https://doi.org/10.1037/0033-295X.95.2.163

Koumachi, B. (2020). Exploring the dynamic interplay between note-taking strategies and reading comprehension performance of Moroccan EFL students: A quasi-experimental study. *Randwick International of Education and Linguistics Science Journal, 1*(2), 159-170. doi:https://doi.org/10.47175/rielsj.v1i2.83

Lyutaya, T. (2011, 2011). *Reading Logs: Integrating Extensive Reading with Writing Tasks.* Paper presented at the English Teaching Forum, US Department of State. Bureau of Educational and Cultural Affairs, Office of English Language Programs, SA-5, 2200 C Street NW 4th Floor, Washinton, DC 20037.

Madjdi, A. H., & Nurcahyo, R. A. D. (2020). *Maintaining reading logs to promote students' reading habits*.

Mansor, M., Adnan, W. A. W., & Abdullah, N. (2019). A Step-by Step Process in Designing Personalized Reading Content for Slow Learner Children. *International Journal of Humanities, Management and Social Science (IJ-HuMaSS), 2*(2), 95-102. doi:https://doi.org/10.36079/lamintang.ij-humass-0202.38

McClure, E. L., & Fullerton, S. K. (2017). Instructional Interactions: Supporting Students′ Reading Development Through Interactive Read-Alouds of Informational Texts. *The Reading Teacher, 0*(0), 1-9. doi:10.1002/trtr.1576

McNamara, V., & Hayden, M. (2022). Education in Cambodia: An Overview. In V. McNamara & M. Hayden (Eds.), *Education in Cambodia: From Year Zero Towards International Standards* (pp. 1-10). Singapore: Springer Nature Singapore.

MoEYS. (2018). *Education in Cambodia: Findings from Cambodia′s experience in PISA for Development*. Phnom Penh: EQAD.

MoEYS. (2020). សៀវភៅណែនាំសម្រាប់គ្រូបង្រៀនថ្នាក់ទី១ [*Guideline for First Grade Teacher*]. Phnom Penh: Ministry of Education, Youth, and Sport.

MoEYS. (2018). Education in Cambodia: Findings from Cambodia′s experience in PISA for Development. Phnom Penh: EQAD.

MoEYS. (2020). Prakas on Komar Rien Komar Cheh [ប្រកាសដាក់ឱ្យប្រើកម្មវិធីកុមាររៀនកុមាររេចះ].

Pak, S. S., & Weseley, A. J. (2012). The Effect of Mandatory Reading Logs on Children's Motivation to Read. *Journal of Research in Education, 22*(1), 251-265.

Palopo, L. (2019). *Note-Taking as a Technique in Teaching Reading Comprehension*.

Perfetti, C., & Stafura, J. (2014). Word Knowledge in a Theory of Reading Comprehension. *Scientific Studies of Reading, 18*(1), 22-37. doi:10.1080/10888438.2013.827687

Rakana, U. (2017). *Effects of the Use of Reading Logs on Reading Comprehension of Mattayomsuksa 5 Students in Trang.* (Master of Art in Teaching English as an International Language), Prince of Songkla University, Prince of Songkla University. Retrieved from

https://kb.psu.ac.th/psukb/bitstream/2016/11728/1/420128.pdf

Reading Eggs. (2023). Reading Log: Where children learn to read. Retrieved from https://readingeggs.co.za/articles/2012-08-22-reading-log/

Ren, Z., Uosaki, N., Kumamoto, E., Liu, G.-Z., & Yin, C. (2017, 2017). *Improving teaching materials through digital book reading log.* Paper presented at the International Conference on Advanced Technologies Enhancing Education (CAT2E 2017).

Ro, E. (2016). Exploring teachers' practices and students' perceptions of the extensive reading approach in EAP reading classes. *Journal of English for Academic Purposes, 22*, 32-41. doi:https://doi.org/10.1016/j.jeap.2016.01.006

Royal-Decree. (2007). ច្បាប់ស្តីពីការអប់រំ [Law for Education]. Royal Affair, 7(93), 9801-9827.

Royal Government of Cambodia. (2015). Sub-Decree on National Reading's Deay [អនុក្រឹត្យស្តីពីទិវាជាតិអំណាន].

Salameh, L. A. M. (2017). Investigating the Effect of Extensive Reading on EFL Learners'Reading Attitudes at Hail University in KSA. *Journal of Education and Practice, 8*(8), 7-15.

Snow, C. (2002). *Reading for understanding: Toward an R&D program in reading comprehension*. Science and Technology Policy Institute: Rand Corporation.

Spencer, M., & Wagner, R. K. (2018). The Comprehension Problems of Children With Poor Reading Comprehension Despite Adequate Decoding: A Meta-Analysis. *Review of Educational Research, 88*(3), 366-400. doi:10.3102/0034654317749187

Valencia, S. (2014). When high school students struggle with textbook reading. Retrieved from https://www.edutopia.org/blog/students-struggle-with-textbook-reading-sheila-valencia

Wilhelm, S. (2021). Reading Logs: Are They Good for the Kids or Should You Log Off? Retrieved from https://www.studentassembly.org/reading-log/

Yanto, E. S., Saefullah, H., & Kwary, D. A. (2020). Implementing a literary text extensive reading program through learning logs. *The Qualitative Report, 25*(5), 1393-1411.